**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**មន្ទីរកសិកម្មខេត្តសៀមរាប**

# របាយការណ៍
## បូកសរុបលទ្ធផលការងារកសិកម្មប្រចាំឆមាសទី១ ឆ្នាំ២០១៦

## I. សភាពការណ៍រួម

ក្នុងរយៈពេល៦ខែដើមឆ្នាំ២០១៦ ពិសេសនារដូវប្រាំងកន្លងមកនេះ បើទោះបីជាអាកាសធាតុមានភាពក្តៅហួតហែងខ្លាំងជាងបណ្តាឆ្នាំកន្លងមកយ៉ាងណាក្តី ក៏ពុំមានបង្កផលប៉ះពាល់អ្វីជាធំដុំដល់ការងារបង្កបង្កើនផលស្រូវរដូវប្រាំងនោះទេ គឺនៅតែទទួលបានលទ្ធផលល្អប្រសើរផងដែរ។ ដោយឡែក នាដើមរដូវវស្សាឆ្នាំ២០១៦នេះ ស្ថានភាពទឹកភ្លៀងមានការអូសបន្លាយយឺតយូរជាងឆ្នាំកន្លងមកបន្តិច តែក៏ពុំមានបញ្ហាអ្វីប៉ះពាល់ដល់ការងារបង្កបង្កើនផលនោះដែរ ពោលគឺនៅតែបង្កឲ្យកសិករអនុវត្តការងារភ្ជួររាស់ដាស់ដី សាបព្រោះដាំដុះដំណាំស្រូវប្រព្រឹត្តទៅបានជាធម្មតា និងបានទាន់ពេលវេលា ពុំមានការថយចុះយឺតយូរជាងឆ្នាំកន្លងមកឡើយ។ ចំពោះវិស័យចិញ្ចឹមសត្វ ដែលបានរួមចំណែកក្នុងការផ្តល់សាច់ធ្វើជាម្ហូបអាហារ និងផ្តល់ប្រាក់ចំណូលបន្ថែមដល់គ្រួសារក្នុងការបង្កើនជីវភាពប្រចាំថ្ងៃ គឺកើតមានជំងឺនៅតាមបណ្តាស្រុកមួយចំនួន ដែលបណ្តាលឲ្យមានការខាតបង់ថវិកាមួយចំនួនរបស់ប្រជាកសិករផងដែរ។

## II.ការងាររដ្ឋបាល-បុគ្គលិក

១.ការងាររដ្ឋបាល

**១.១ លិខិតចូល៖** - បានទទួលលិខិតចូលសរុប ៦៣០ ច្បាប់

**១.២ លិខិតចេញ៖** - បានចុះលិខិតចេញសរុប ៤៣៩ ច្បាប់
- ចម្លងលិខិតទៅអង្គភាពក្រោមឱវាទមន្ទីរសរុបបាន ៧៦ ច្បាប់
- បញ្ជូនលិខិតទៅអង្គភាពជុំវិញខេត្ត ៧៦ច្បាប់
- ធ្វើលិខិតឧទ្ទេសនាមសរុប២៤២លើក ក្នុងនោះចេញក្រៅខេត្ត៦៧លើក ក្នុងខេត្ត១៦៥លើក។

**១.៣ ការចូលរួមទទួលប្រតិភូ សម្ពោធ មីទ្ទិញ និងការងារសង្គមផ្សេងៗ ៖** សរុប ៩៣លើក។

**១.៤ ការចូលរួមប្រជុំ ប្រកាស សិក្ខាសាលា និងសន្និបាត ៖** សរុប ១២៥លើក។

២.ការងារបុគ្គលិក

២.១ ស្ថានភាពក្របខណ្ឌ

ក.ក្របខណ្ឌ

- ក្របខ័ណ្ឌដើមឆមាសទី១ ឆ្នាំ២០១៦ សរុបចំនួន១៣៧នាក់(ស្រី ៣៦នាក់) ក្នុងនោះ៖

.ថ្នាក់មន្ទីរ ៨៨នាក់ ស្រី ២៣នាក់

.ថ្នាក់ស្រុក ៤៩នាក់ ស្រី ១៣នាក់

-ការប្រែប្រួល ៖

.ផ្ទេរចូល ៖ ០៣នាក់

.ផ្ទេរចេញ ៖ ០២នាក់

.ចូលនិវត្តន៍ ៖ ០៤នាក់

.សុំលាឈប់ ៖ ០៣នាក់

.ទទួលមរណភាព៖ គ្មាន

.ការប្តូរ៖ មន្ត្រី០១នាក់ ផ្ទេរពីកសិកម្មស្រុកជីក្រែង មកការិយាល័យរដ្ឋបាស-បុគ្គលិកនៃមន្ទីរកសិកម្ម

-ក្របខណ្ឌដែលមានចុងឆមាសទី១ ឆ្នាំ២០១៦ សរុបចំនួន ១៣១នាក់ (ស្រី ៣៤នាក់) ក្នុងនោះ ៖

.ថ្នាក់មន្ទីរ ៨៤នាក់ ស្រី ២២នាក់

.ថ្នាក់ស្រុក ៤៧នាក់ ស្រី ១២នាក់

**ខ. មន្ត្រីជាប់កិច្ចសន្យា និងពលករអណ្តែក**

មន្ត្រីជាប់កិច្ចសន្យាមាន១០នាក់(ស្រី ០៥នាក់) ។

**គ.អ្នកបច្ចេកទេស**

| លរ | ឋាន: | កំរិតសិក្សា | | | | | វគ្គខ្លីៗ | សរុប |
|---|---|---|---|---|---|---|---|---|
| | | បណ្ឌិត | អនុបណ្ឌិត | បរិញ្ញា | មធ្យម | បឋម | | |
| ១ | ថ្នាក់ដឹកនាំមន្ទីរ | ១ | ២ | ១ | ១(១) | - | - | ៥នាក់(ស្រី១) |
| ២ | ប្រធានការិយាល័យ | ១ | ៥ | ១ | - | - | - | ៧នាក់ |
| ៣ | អនុប្រធានការិយាល័យ | - | ១ | ២ | - | ១ | ១(១) | ៥នាក់(ស្រី១) |
| ៤ | ប្រធានការិ.កសិកម្មក្រុង-ស្រុក | - | - | ២(១) | ២ | ៣ | ១ | ៨នាក់(ស្រី១) |
| ៥ | អនុប្រធានការិ.កសិកម្មក្រុង-ស្រុក | - | ១ | ១ | ២ | ៣(១) | ៧(២) | ១៤នាក់(ស្រី៣) |
| ៦ | មន្ត្រីថ្នាក់ខេត្ត | - | ១១(៣) | ១៧(២) | ១៧(៤) | ៩(៣) | ១៤(៨) | ៦៨នាក់(ស្រី២០) |
| ៧ | មន្ត្រីថ្នាក់ស្រុក | - | - | ២(២) | ៣ | ៣(១) | ១៦(៥) | ២៤នាក់(ស្រី៨) |
| សរុប | | ២ | ២០(៣) | ២៦(៥) | ២៥(៥) | ១៩(៥) | ៣៩(១៦) | ១៣១នាក់(ស្រី៣៤) |

**២.២ ការងារបណ្តុះបណ្តាល**

**ក.ការបណ្តុះបណ្តាលក្នុងប្រទេស៖** មន្ត្រីដែលកំពុងបណ្តុះបណ្តាលក្នុងប្រទេសមាន ថ្នាក់បរិញ្ញាបត្រ០១នាក់។

**ខ.ការបណ្តុះបណ្តាលក្រៅប្រទេស៖** ០១នាក់ វគ្គខ្លីៗ នៅប្រទេសថៃ ។

## III>ការងារផែនការ-គណនេយ្យ

### ១.ការងារផែនការ-ស្ថិតិ

- ស្រង់ស្ថិតិតម្លៃផលិតផលកសិកម្ម៥ថ្ងៃ/សប្តាហ៍ដែលស្រង់តម្លៃលក់រាយប្រមាណ៥០មុខ(១ដង/សប្តាហ៍) និងតម្លៃលក់ដុំចំនួន ៣៥មុខ (៣ដង/សប្តាហ៍) ផ្ញើជូនក្រសួង និងអង្គភាពពាក់ព័ន្ធ។

– ស្រង់ និងបូកសរុបលទ្ធផលនៃការអង្កេតវាស់ស្ទង់ទិន្នផលស្រូវរដូវវស្សាឆ្នាំ២០១៥ របស់ខេត្តសៀមរាប មានចំនួន១២ក្រុង-ស្រុក ១៤៨ភូមិ ៤៤៤គ្រួសារ ស្មើនឹង១.៧៨៧សំណាក ទទួលបានទិន្នផលស្រូវជាមធ្យម ២,៥២៧ត/ហ.ត (ស្រូវស្រាល២,៣៧៧ត/ហ.ត ស្រូវកណ្តាល២,៤៩៣ត/ហ.ត ស្រូវធ្ងន់ ២,៨០៣ត/ហ.ត ស្រូវចម្ការ២,២៧៨ត/ហ.ត និងស្រូវវារ២,៣៩៩ត/ហ.ត)។
– ផ្តល់ឯកសារសម្រាប់ការអង្កេតវាស់ស្ទង់ទិន្នផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦ ដល់មន្ត្រីជំនាញកសិកម្មក្រុង-ស្រុកទាំង០៦ ដែលស្មើនឹង១៤ភូមិ ត្រូវនឹង៤២គ្រួសារ និងត្រូវជា១៦៨សំណាក ។ លទ្ធផលនៃការអង្កេតវាស់ស្ទង់ ទទួលបានទិន្នផលជាមធ្យម ៣,៤០១ត/ហ.ត និងបរិមាណផលចំនួន ៧១.៣៧៧តោន។
– រៀបចំឯកសារ បូកសរុប វិភាគទិន្នន័យ ធ្វើរបាយការណ៍ប្រចាំឆ្នាំ និងធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៥ឆ្នាំ (ឆ្នាំ២០១៦-២០២០( និងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧-២០១៩ របស់មន្ទីរកសិកម្មខេត្តសៀមរាប។
– ចូលរួមសិក្ខាសាលាស្តីពី ការពិនិត្យឡើងវិញនៃសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម សម្រាប់ មន្ទីរកសិកម្មរាជធានី-ខេត្ត ២០១៦-២០២០។
– ការិយាផែនការ-គណនេយ្យ និងការិយាល័យជំនាញនៃមន្ទីរកសិកម្មខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋានចុះចែកពូជស្រូវ និងសម្ភារៈកសិកម្មជូនដល់កសិករចំនួន៥ឃុំ នៅក្នុងក្រុង-ស្រុកចំនួន២ គឺ ក្រុងសៀមរាប និងស្រុកជីក្រែង ក្រោមគម្រោងឥណទានជួយសង្គ្រោះឆ្នាំ២០១៦ ដែលប្រព្រឹត្តទៅ៖
    1. ក្រុងសៀមរាប៖ ស្ថិតនៅក្នុងសង្កាត់ចំនួន៤ គឺសង្កាត់ក្របីរៀល សំបួរ ស្រង៉ែ និងសង្កាត់ជ្រាវ បានចុះចែកពូជស្រូវសែនពិដោរ និងជីគីមីជូនដល់កសិករ ចំនួន១៥០គ្រួសារ ក្នុងមួយគ្រួសារទទួលបានពូជស្រូវចំនួន២០គីឡូក្រាម និងជីគីមី៥០គីឡូក្រាម។
    2. ស្រុកជីក្រែង៖ ស្ថិតនៅក្នុងភូមិត្រពាំងត្រស់ ឃុំអន្លង់សំណរ ស្រុកជីក្រែង បានចុះចែកពូជស្រូវសែនពិដោរ ថ្នាំកណ្តុរ និងសំបកការ៉ុង ជូនដល់កសិករចំនួន១០៨គ្រួសារ ដែលក្នុងមួយគ្រួសារទទួលបានពូជស្រូវចំនួន២០គីឡូក្រាម ចំនែកឯថ្នាំកណ្តុរចំនួន៨០គីឡូក្រាម និងសំបកការ៉ុងចំនួន៤.០០០សំបក រក្សាទុកនៅក្នុងសាលាឃុំអន្លង់សំណរ ដើម្បីទុកប្រតិបត្តិការរួមនៅពេលដែលមានបញ្ហាកើតមានឡើងនៅក្នុងឃុំ។ ក្នុងនោះដែរ មន្ទីរកសិកម្មបានជ្រើសរើសកសិករគំរូចំនួន២៦នាក់ ដើម្បីលើកក្តីស្រែ និងក្ជួរដាស់ជីជាគំរូបង្ហាញដល់គ្រួសាដែលចូលរួមក្នុងកម្មវិធី ហើយកសិករទាំង២៦នាក់ ទទួលបានផ្លែចបមួយ និងក្រមាមួយ ផងដែរ។

## ២.ការងារទីផ្សារ

តម្លៃជាមធ្យមនៃផលិតផលកសិកម្មលក់រាយនៅលើទីផ្សារ(ផ្សារលើធំថ្មី) ក្នុងក្រុងសៀមរាប ខេត្តសៀមរាប រួមមាន៖

### ក. បន្លែ

| | | |
|---|---|---|
| -ផៃថាវ៣.០០០៛/គ.ក្រ | -ម្រះ២.៨០០៛/គ.ក្រ | -ស្ពៃក្តោប២.៥០០៛/គ.ក្រ |
| -ខាត់ណា៤.១០០៛/គ.ក្រ | -ត្រសក់១.៨០០៛/គ.ក្រ | -ត្រឡាច ២.០០០៛/គ.ក្រ |
| -ប៉េងបោះ២.៩០០៛/គ.ក្រ | -សណ្តែកកួរ៥.៥០០៛/គ.ក្រ | -ត្រកួនចិន២.០០០៛/គ.ក្រ |
| -ស្ពៃខៀវ៣.៣០០៛/គ.ក្រ | - ស្ពៃក្រញ៉ាញ់៣.៨០០៛/គ.ក្រ | -ផ្កាខាត់ណា៥.៦០០៛/គ.ក្រ |
| -ការ៉ុត ៣.៣០០ ៛/គ.ក្រ | -ស្ពៃចង្កឹះ២.៨០០៛/គ.ក្រ | |

ខ. ប្រភេទសាច់

| | | |
|---|---|---|
| -សាច់មាន់២២.៩០០៛/គ.ក្រ | -ត្រីឆ្តោររស់១៦.៣០០៛/គ.ក្រ | -ត្រីអណ្តែងរស់១៥.៥០០៛/គ.ក្រ |
| -សាច់ទា១៤.៨០០៛/គ.ក្រ | -ត្រីឡឹបរស់១៥.៥០០៛/គ.ក្រ | -ត្រីងៀតត្រីឆ្តោរ៥៩.៥០០៛/គ.ក្រ |
| -សាច់គោ៣៦.០០០៛/គ.ក្រ | -ត្រីរ៉សរស់១៧.០០០៛/គ.ក្រ | -ត្រីងៀតត្រីឡឹប៥៣.៧០០៛/គ.ក្រ |
| -សាច់ជ្រូកបីជាន់១៣.១០០៛/គ.ក្រ | -ពងមាន់៤៧៨៛/គ្រាប់ | -ពងទា៥៥០៛/គ្រាប់ |

គ. ប្រភេទអង្ករ

| | | |
|---|---|---|
| -អង្ករបំបុះ១.៦៥០៛/គ.ក្រ | -អង្ករផ្កាខ្ញី១.៨០០៛/គ.ក្រ | -អង្ករសូម៉ាលី២.៤០០៛/គ.ក្រ |
| -អង្ករផ្ការំដួល២.៤០០៛/គ.ក្រ | -អង្ករសែនពិដោរ២.០០០៛/គ.ក្រ | -អង្ករផ្កាម្លិះ២.៤០០៛/គ.ក្រ |

ឃ. ប្រភេទជីកសិកម្ម (គិតក្នុងទម្ងន់៥០គ.ក្រ)

| | |
|---|---|
| -ជី15-15-15 (ថៃ)១២៥.០០០៛ | -ជី16-20-00 (ថៃ)១២១.០០០៛ |
| -ជីDAP ឬ18-46-00(អាមេរិក)១២៥.០០០៛ | -ជី46-00-00 (ថៃ)១៣០.០០០៛ |

## IV>ការងារក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម

### ១.ការប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៥

- ធ្វើបានសរុប**១៨៦.០៥០ហ.ត** ស្មើនឹង**១០១%** នៃផែនការ១៨៤.២០០ហ.ត ។

- ប៉ះពាល់ដោយគ្រោះរាំងស្ងួត និងខូចខាតទាំងស្រុងសរុបចំនួន៨៣០ហ.ត លើស្រុក-ក្រុងចំនួន០៣គឺ ក្រុងសៀមរាបចំនួន២០០ហ.ត ស្រុកក្រឡាញ់ ចំនួន៥៧០ហ.ត និងស្រុកអង្គរធំចំនួន៦០ហ.ត លើប្រភេទស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់ ។

-ដូចនេះផ្ទៃដីដំណាំស្រូវវស្សាឆ្នាំ២០១៥ ដែលត្រូវប្រមូលផលចំនួន**១៨៥.២២០ហ.ត**។

-បានប្រមូលផលស្រូវរដូវវស្សាសរុប១៨៥.២២០ហ.ត ដោយទទួលបានទិន្នផលជាមធ្យម ២,៥២៧តោន/ហ.ត និងបានបរិមាណផលសរុប៤៦៨.១០៩តោន ប្រៀបធៀបឆ្នាំមុន(វស្សា២០១៤) ២,៦៣៣ត/ហ.ត ដូចនេះទាបជាង ០,១០៦ត/ហ.ត និងបរិមាណផលតិចជាងចំនួន១៦.៥០៦តោន ក្នុងនោះ ៖

| | | |
|---|---|---|
| -ស្រូវស្រាល | ៣៨.៣៦៥ហ.ត | ទិន្នផលជាមធ្យម ២,៣៧៧ត/ហ.ត |
| -ស្រូវចំការ | ៥.៤៣០ហ.ត | ទិន្នផលជាមធ្យម ២,២៧៨ត/ហ.ត |
| -ស្រូវកណ្តាល | ៩៣.២៣០ហ.ត | ទិន្នផលជាមធ្យម ២,៤៩៣ត/ហ.ត |
| -ស្រូវធ្ងន់ | ៤០.៩៣៥ហ.ត | ទិន្នផលជាមធ្យម ២,៨០៣ត/ហ.ត |
| -ស្រូវវារ | ៧.២៦០ហ.ត | ទិន្នផលជាមធ្យម ២,៣៩៩ត/ហ.ត |

### ២.ការងារបង្កបង្កើនផលរដូវប្រាំងឆ្នាំ២០១៥-២០១៦

២.១ ដំណាំស្រូវ

-ភ្ជួរសរុបបាន២២.៦៨០ហ.ត ក្នុងនោះ ភ្ជួរដោយគ្រឿងយន្ត២២.៥៣០ហ.ត

-សាបបានសរុប ០ ហ.ត

-ធ្វើបានសរុប ២០.៩៨៥ហ.ត ស្មើនឹង១០០,២៩% នៃផែនការ២០.៩២៥ហ.ត ក្នុងនោះ ស្រូវបង្កើនរដូវ ២៩០ហ.ត ស្រូវប្រដេញទឹក៥.០១០ហ.ត(ពង្រោះទាំងអស់) និងស្រូវប្រាំងរនាម១៥.៦៨៥ហ.ត(ពង្រោះទាំងអស់)។

**-ការប៉ះពាល់៖** ការប៉ះពាល់ដំណាំស្រូវដោយសារខ្វះទឹកចំនួន៤០០ហ.ត នៅ២ស្រុក-ក្រុង គឺក្រុងសៀមរាប និងស្រុកពួក បន្ទាប់ពីអង្គភាពជំនាញនិងកសិករបានបញ្ជូនបញ្ចូលទឹក និងបូមស្រោចស្រពទៅវិញជាបន្តបន្ទាប់ ធ្វើឲ្យដំណាំស្រូវពុំមានបញ្ហាខូចខាតអ្វីជាធំដុំនោះទេ ។

-បានច្រូតកាត់ប្រមូលផលស្រូវវស្សាប្រាំងនេះសរុបចំនួន២០.៩៨៥ហ.តស្មើនឹង១០០.០០% នៃផ្ទៃដីអនុវត្តបាន ២០.៩៨៥ហ.ត ដោយប៉ាន់ស្មានទិន្នផលជាមធ្យម ៣,៤០១តោន/ហ.ត និងបរិមាណផល ៧១.៣៧៧តោន ។

**២.២ ដំណាំរួមផ្សំ**

ដំណាំរួមផ្សំដាំបានសរុបចំនួន**៩.៨៧៥ហ.ត** ស្មើនឹង**១២១,៩១%** នៃផែនការ៨.១០០ហ.ត ក្នុងនោះ ពោត៦៣០ ហ.ត ដំឡូងមី៣.៨០៣ហ.ត ដំឡូងជ្វា២៥០ហ.ត បន្លែគ្រប់មុខ១.៣៩៩ហ.ត អំពៅ១៦៦ហ.ត ល្ង១៥ហ.ត សណ្តែកសៀង៦៣០ហ.ត សណ្តែកបាយ២.៤៦៥ហ.ត និងឪឡឹក៥១៧ហ.ត។

## ៣. ការវាយតម្លៃតុល្យភាពស្បៀងសម្រាប់ឆ្នាំ២០១៥-២០១៦

| បរិយាយ | កំរិតកំណត់ | ឯកត្តា | សរុប |
|---|---|---|---|
| លទ្ធផលទទួលបាន (ស្រូវវស្សា និងវស្សាប្រាំង) | ផ្ទៃដីអនុវត្តបាន | ហ.ត | ២០៧.០៣៥ |
| | ផ្ទៃដីខូចខាត | ហ.ត | ៨៣០ |
| | ដីស្តារបាន | ហ.ត | ០ |
| | ផ្ទៃដីប្រមូលផល | ហ.ត | ២០៦.២០៥ |
| | ទិន្នផលមធ្យម | តោន/ហ.ត | ២,៦១៦ |
| | បរិមាណផល | តោន | ៥៣៩.៤៨៦ |
| ការវាយតម្លៃស្បៀងសម្រាប់ឆ្នាំ ២០១៦ | ប្រជាជន | នាក់ | ៩៣៩.៨៣៩ |
| | បាត់បង់ ទុកពូជ ចិញ្ចឹមសត្វ ១៣% | តោន | ៧០.១៣៣ |
| | តម្រូវការស្បៀង ជាអង្ករ ១៤៣គ.ក្រ/ន/ឆ្នាំ | តោន | ១៣៤.៣៩៧ |
| | តុល្យភាពស្បៀង(សល់) ជាអង្ករ | តោន | ១៦៥.៩៨៩ |

**បញ្ជាក់៖** យោងលើការធ្វើចន្លោះដំរឿនប្រជាជនឆ្នាំ ២០១៣ និងការធ្វើចំណោលឆ្នាំ២០១៦ របស់ក្រសួងផែនការ។

## ៤.ការងារបង្កបង្កើនផលវស្សាឆ្នាំ២០១៦ (គិតត្រឹមថ្ងៃទី២១.៦.២០១៦)

**៤.១ ស្ថានភាពទឹកភ្លៀង**

-ស្ថានភាពទឹកភ្លៀងនារដើមវស្សានេះមានការអូសបន្លាយយឺតយូរជាងឆ្នាំកន្លងមក តែក៏ពុំមានបញ្ហាអ្វីធ្ងន់ធ្ងរដល់ការងារបង្កបង្កើនផលនោះទេ ពោលគឺនៅតែបង្កឲ្យកសិករអនុវត្តការងារភ្ជួររាស់ដាស់ដី និងសាបព្រោះដាំដុះដំណាំស្រូវប្រព្រឹត្តទៅបានជាធម្មតា និងបានទាន់ពេលវេលា។

-កំរិតកម្ពស់ទឹកភ្លៀងនៅស្ថានីយ៍ឧតុនិយមខេត្ត (នៅបុរីរដ្ឋបាល) គិតពីដើមឆ្នាំ ដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០១៦ មានកម្ពស់១៨៩,៨ម.ម ស្មើនឹង២៤ថ្ងៃ ប្រៀបធៀបនឹងឆ្នាំ២០១៥ ក្នុងរយៈពេលដូចគ្នា(១៩៦,៧ម.ម=១៨ ថ្ងៃ) គឺឆ្នាំនេះមានកម្ពស់ទាបជាង ៦,៩ម.ម តែចំនួនថ្ងៃច្រើនជាង ០៦ថ្ងៃ។

**៤.២ ការងារបង្កបង្កើនផលវស្សាឆ្នាំ២០១៦**

- ភ្ជួរដាស់ដីបាន ១១៣.០៥០ហ.ត ក្នុងនោះ ភ្ជួរដោយគ្រឿងយន្តកសិកម្ម១០៥.០៦៥ហ.ត។
- សាបបាន ៤៨៥ហ.ត (ស្រូវស្រាល ៩០ហ.ត, កណ្តាល២៣០ហ.ត, និងធ្ងន់១៦៥ហ.ត)។
- ធ្វើបានសរុប **៧៨.៥៣០ហ.ត** ស្មើនឹង **៤២,១៨%**នៃផែនការ ១៨៦.២០០ហ.ត បើប្រៀបធៀបនឹងឆ្នាំមុនរយៈពេលដូចគ្នា(៧៥.៥៧០ហ.ត) ឆ្នាំនេះអនុវត្តបានច្រើនជាង ២.៩៦០ហ.ត ក្នុងនោះ៖

.ដាំស្រូវចំការ ១.៨២៥ហ.ត

.ព្រោះស្រូវវារ ៦.៣២៥ហ.ត

.ស្រូវស្រាល ៩.១៩០ហ.ត (ពង្រោះទាំងអស់ )

.ស្រូវកណ្តាល  ៤១.៧៧៥ហ.ត (ពង្រោះទាំងអស់)

.ស្រូវធ្ងន់១៩.៤១៥ហ.ត (ពង្រោះ១៩.៣៩០ហ.ត)។

**៤.៣ ដំណាំរួមផ្សំ**

ដំណាំរួមផ្សំដាំបានចំនួន**១៦.៥៧០ហ.ត ស្មើនឹង ១២៩,១០%** នៃផែនការ១២.៨៣៥ហ.ត ក្នុងនោះ ពោត ២៥៩ហ.ត ដំឡូងមី១២.៥៥៦ហ.ត ដំឡូងជ្វា២០០ហ.ត បន្លែគ្រប់មុខ៦៦៥ហ.ត អំពៅ៣១៣ហ.ត ល្ង៨០ហ.ត សណ្តែកសៀង២០ហ.ត សណ្តែកបាយ២.៣១៣ហ.ត និងឪឡឹក១៦៤ហ.ត។

**៤.៤ បញ្ហាជួបប្រទះ**

- នៅភូមិស្លែង ឃុំស្រណាល ស្រុកក្រឡាញ់ មានការប៉ះពាល់ស៊ីបំផ្លាញពីដង្កូវហ្វូងលើផ្ទៃដីស្រូវធ្ងន់ចំនួន៦០ហ.ត ។ នៅភូមិល្បើកប្រើយ៍ ភូមិព្រៃគាប ភូមិខ្នាយ ឃុំរោងគោ និងឃុំស្នួល ស្រុកក្រឡាញ់ មានការស៊ីបំផ្លាញស្រូវពីដង្កូវហ្វូងតិចតួច ។

-នៅភូមិកំព្រហ្ម ឃុំយុនរាម និងភូមិអូរម្នាស់ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ដែលមានដង្កូវហ្វូងស៊ីបំផ្លាញប៉ះពាល់លើដំណាំសណ្តែកបាយចំនួន២០ហ.ត ។

-នៅភូមិកិត្តិយស ប្រនាង ប្រេស និងភូមិព្រៃជ្រូក ឃុំព្រៃជ្រូក ស្រុកពួក មានដង្កូវហ្វូងស៊ីបំផ្លាញ ប៉ះពាល់លើដំណាំស្រូវចំនួន៣០ហិកតា ។

- នៅភូមិប្រើយ៍១ ឃុំប្រើយ៍ និងភូមិជ្រោយនាងងួន ឃុំជ្រោយនាងងួន ស្រុកស្រីស្នំ មានការស៊ីបំផ្លាញស្រូវពីដង្កូវហ្វូងតិចតួច

**+ ការបំផ្លាញដំណាំស្រូវ និងដំណាំរួមផ្សំរបស់ដង្កូវហ្វូង**នៅតាមបណ្តាភូមិ ឃុំ ក្នុងស្រុកខាងលើ មានការថយចុះជាបន្តបន្ទាប់ ក្រោយពីមានភ្លៀងធ្លាក់ជោកជាំ និងការបាញ់ថ្នាំកម្ចាត់ ហើយសភាពដំណាំទាំងនោះមានការដុះលូតលាស់ឡើងវិញជាបណ្តើរៗហើយ។

**៤.៥ វិធានការបានអនុវត្ត**

ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីជំនាញខេត្ត ស្រុកបានចុះត្រួតពិនិត្យ តាមដាន និងណែនាំដល់កសិករពីវិធានការកម្ចាត់ដង្កូវហ្វូងនោះជាបន្តបន្ទាប់ ដូចជា ការជីកចង្អូរពោយផេះទប់ស្កាត់ការឆ្លងរាលដាលពីកន្លែងមួយទៅកន្លែងមួយ ការប្រើប្រាស់មាន់ទាឲ្យស៊ី និងការប្រើថ្នាំពុលកសិកម្មកម្ចាត់ជាដើម។

## V. ការងារផលិតកម្ម និងបសុពេទ្យបាល

### ១-ការងារផលិតកម្ម

**ក.ស្ថិតិសត្វគ្រប់ប្រភេទ**

| | | | |
|---|---|---|---|
| -គោសរុប | ២៤០.៧៧០ក្បាល | គោអូសទាញ | ៩៥.១៤០ក្បាល |
| -ក្របីសរុប | ៣០.៧១០ក្បាល | ក្របីអូសទាញ | ១៦.៥៣៩ក្បាល |
| -គោក្របីសរុប | ២៧១.៤៨០ក្បាល | គោក្របីអូសទាញសរុប | ១១១.៦៧៩ក្បាល |
| -សេះសរុប | ១១៨ក្បាល | | |
| -ដំរីសរុប | ១២ក្បាល | | |
| -ពពែចៀមសរុប | ១៥៥ក្បាល | | |
| -ជ្រូកសរុប | ១៦៤.០៩៣ក្បាល | | |

-សត្វស្លាបសរុប ២.៥៦៥.៤៦០ក្បាល មានមាន់២.០១៤.៥៥០ក្បាល ទា៥៤៩.៧២០ក្បាល ក្ងាន៧៧០ក្បាល ព្រាប៤២០ក្បាល មានលទ្ធភាពផ្តល់ស៊ុតះ មាន់១៥.០០០គ្រាប់/ថ្ងៃ ទា១២០.០០០គ្រាប់/ថ្ងៃ។

**ខ.ស្ថិតិកសិដ្ឋានចិញ្ចឹមសត្វ ៖ ក្នុងទូទាំងខេត្តមាន**

-ការចិញ្ចឹមមាន់ស៊ុតសាច់ជាលក្ខណៈកសិដ្ឋានគ្រួសារមាន៤៣កន្លែងមានមាន់ប្រមាណ៤៤០.០០០ក្បាល។

-ការចិញ្ចឹមទាហ្វូង មាន១១៨កន្លែង មានទាប្រមាណ២២៧.១០០ក្បាល។

-ការចិញ្ចឹមជ្រូក៤៨កន្លែង មានជ្រូកប្រមាណ៥៧.០៥០ក្បាល។

-ការចិញ្ចឹមពពែ ចៀម មាន៥កន្លែង មានពពែ ចៀម ១៥៥ក្បាល។

**-ក្នុងឆមាសទី១ ឆ្នាំ២០១៦** ការសាងសង់ឡជីវឧស្ម័នបានចំនួន៤៩ឡ(ស្រុកជីក្រែង៨ឡ ស្រុកសូទ្រនិគម ២៩ឡ ស្រុកប្រាសាទបាគង១ឡ ក្រុងសៀមរាប៦ឡ ស្រុកពួក៥ឡ )។ បូកយោងធ្វើបាន៤៩ឡ ។

**គ.តម្លៃសត្វ**

-ជ្រូករស់ថ្លៃមធ្យម១០០០០៛/គ.ក្រ សាច់ជ្រូកថ្លៃមធ្យម១៧០០០៛/គ.ក្រ

-គោក្របីថ្លៃមធ្យម១៥០០០៛/គ.ក្រ សាច់គោថ្លៃមធ្យម៣៥០០០៛/គ.ក្រ

-មាន់រស់ថ្លៃមធ្យម២០០០០៛/គ.ក្រ សាច់មាន់ថ្លៃមធ្យម២៥០០០៛/គ.ក្រ

-ទារស់ថ្លៃមធ្យម១២០០០៛/គ.ក្រ សាច់ទាថ្លៃមធ្យម១៥០០០៛/គ.ក្រ

-ស៊ុតមាន់ថ្លៃមធ្យម៤០០៛/គ្រាប់ ស៊ុតទាថ្លៃមធ្យម៤៥០៛/គ្រាប់

-ខ្លាញ់ជ្រូកថ្លៃមធ្យម៦០០០៛/គ.ក្រ

**ឃ.តម្លៃវត្ថុធាតុដើមផ្សំចំណីសត្វ**

-កន្ទក់ថ្លៃមធ្យម៦០០៛/គ.ក្រ -ចុងអង្ករ ថ្លៃមធ្យម១០០០៛/គ.ក្រ

-ពោតថ្លៃមធ្យម១២០០៛/គ.ក្រ -សណ្តែកសៀងថ្លៃមធ្យម២៣០០៛/គ.ក្រ

-ម្សៅត្រីថ្លៃមធ្យម៣៣០០៛/គ.ក្រ

**២.ការងារសុខភាពសាធារណៈ**

-ត្រួតពិនិត្យចរន្តសត្វ អនាម័យសាច់ និងគ្រប់គ្រងការធ្វើអាជីវកម្មសត្វ និងបសុផល ដើម្បីធានាសុខភាពសាធារណៈជាប្រចាំ នៅសត្តឃាតដ្ឋានក្រុងសៀមរាប និងបណ្តាស្រុកផ្សេងទៀត ។ បានធ្វើការបំផ្លាញចោលនូវផ្នែកដែលមានជំងឺ ៖

+ជ្រូក ៖ សួត២៤មានដាំឈាម និងក្រិន ថ្លើម៦ក្រិនមានបូស ក្រលៀន១២គូហើមធំ ។

+គោក្របី ៖ ផាលចំនួន១៥ ហើមធំនិងដាំឈាម ថ្លើម៧ក្រិនមានបូស ។

-ចាត់តាំងមន្ត្រី០១នាក់ត្រួតពិនិត្យអនាម័យសត្វនិងផលិតផលសត្វនៅអាកាសយានដ្ឋានសៀមរាប។

-ចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វចំនួន១៦៥នាក់ និងលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ១នាក់។

**ក.ចរន្តសត្វនិងផលិតផលសត្វ**

| ប្រភេទសត្វ និង ផលិតផល | ការដឹកនាំចេញ | |
|---|---|---|
| | **ចំនួន** | **ទិសដៅ** |
| គោក្របីរស់ | ២.៤១១ក្ប | ពីស្រុកជីក្រែង ស្រុកសូទ្រនិគម ស្រុកស្រីស្នំ ស្រុកពួក ស្រុកវ៉ារិន ស្រុកក្រឡាញ់ ទៅខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ និងរាជធានីភ្នំពេញ |
| ជ្រូករស់ | ៩.៩៦៥ក្ប | ពីស្រុកអង្គរធំ ស្រុកបន្ទាយស្រី ស្រុកជីក្រែង ទៅខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តកណ្តាល និងរាជធានីភ្នំពេញ |
| មាន់រស់ | ១៨៧.៩៨៦ក្ប | ពីស្រុកជីក្រែង ស្រុកបន្ទាយស្រី ស្រុកប្រាសាទបាគង ក្រុងសៀមរាប ទៅ |

| | | |
|---|---|---|
| | | ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ |
| ស្បែកគោក្របី | ២២.៧០០គ.ក្រ | ពីក្រុងសៀមរាប ទៅភ្នំពេញ |

**ខ.ចំនួនសត្វពិឃាដ**

| កន្លែងពិឃាត | ជ្រូក | | គោក្របី | | |
|---|---|---|---|---|---|
| | ចំនួន(ក្បាល) | ទម្ងន់សាច់(គ.ក្រ) | គោ(ក្បាល) | ក្របី(ក្បាល) | ទម្ងន់សាច់(គ.ក្រ) |
| ក្រុងសៀមរាប | ១៣.៤០៨ | ៧៦៥.២៨០ | ២.៧៥៨ | ១៥៩ | ២៣២.៦៦០ |
| បណ្តាស្រុក | ១០.៣០២ | ៥៨៥.០៦០ | ៩៧៨ | ០ | ៧៧.៤៩០ |
| **សរុប** | **២៣.៧១០** | **១.៣៥០.៣៤០** | **៣.៧៣៦** | **១៥៩** | **៣១០.១៥០** |

**៣.ការងារបសុព្យាបាល**

**ក. ស្ថានភាពជំងឺសត្វ៖** ក្នុងអំឡុងខែមករា និងដើមខែមិថុនា ឆ្នាំ២០១៦ជម្ងឺសត្វមានកើតឡើងរប៉េះរប៉ោះដូចជា៖

**គោ ៖** -ជម្ងឺសារទឹក៖ មានកើតនៅស្រុកក្រឡាញ់(ឃុំស្រណាល,ឃុំចន្លាសដៃ,ឃុំកំពង់ថ្កូវ, ឃុំសំបួរ,ឃុំតាអាន, ឃុំរោងគោ,ឃុំស្នួល) ស្រុកបន្ទាយស្រី (ឃុំព្រះដាក់,ឃុំខ្នារសណ្តាយ,ឃុំត្បែង,ឃុំឃុនរាម) និងស្រុកប្រាសាទ-បាគង(ឃុំរលួស,ឃុំមានជ័យ,ឃុំកណ្តែក) បណ្តាលឲ្យគោឈឺចំនួន១០០ក្បាល និងក្របី១៦ក្បាល ក្នុងនោះងាប់គោ១៦ក្បាល និងក្របី១ក្បាល។

-ជម្ងឺបូសខ្យល់ ៖មានកើតនៅស្រុកជីក្រែង(ឃុំគោកធ្លកក្រោម,ឃុំល្វែងឫស្សី,ឃុំឫស្សីលក,ឃុំពង្រលើ, ឃុំខ្វាវ) បណ្តាលឲ្យគោឈឺចំនួន៥០ក្បាល ក្នុងនោះងាប់គោ១៥ក្បាល ។

-ជម្ងឺអុតក្តាម៖ មានកើតនៅស្រុកស្រីស្នំ (ឃុំស្លែងស្ពាន) បណ្តាលឲ្យឈឺគោ៥ក្បាល មិនមានងាប់ទេ។

-ជម្ងឺរាគឈាម៖ មានកើតនៅស្រុកបន្ទាយស្រី(ឃុំខ្នារសណ្តាយ) និងស្រុកពួក(ឃុំត្រីញ័រ)បណ្តាលឲ្យគោឈឺ១៣ក្បាល ក្នុងនោះងាប់គោ២ក្បាល។

**សរុបគោឈឺ១៦៨ក្បាល ក្របី១៦ ក្នុងនោះ ងាប់គោ ៣៣ក្បាល និងក្របី១ក្បាល។**

**ជ្រូក ៖** -**ជម្ងឺប៉េស្ត-សារទឹក៖** មានកើតនៅស្រុកក្រឡាញ់(ឃុំសំបួរ,ឃុំតាអាន) ស្រុកបន្ទាយស្រី(ឃុំព្រះដាក់, ឃុំត្បែង) ស្រុកស្វាយលើ(ឃុំស្វាយលើ,ឃុំបឹងមាលា,ឃុំតាសៀម) បណ្តាលឲ្យជ្រូកឈឺ៨៦ក្បាល ក្នុងនោះងាប់ជ្រូក៦ក្បាល និងជ្រូកបានសម្លាប់២ក្បាល។

-**ជម្ងឺអូស្សេស្ដី៖** កើតនៅស្រុកពួក(ឃុំពួក)បណ្តាលឲ្យជ្រូកឈឺ៣០ក្បាលក្នុងនោះងាប់ជ្រូក៤ក្បាល ។

-**ជម្ងឺស្ត្រិបតូកុក៖** មានកើតនៅស្រុកពួក(ឃុំរើល) បណ្តាលឲ្យជ្រូកឈឺ២ក្បាល មិនមានងាប់ទេ ។

-**ជម្ងឺរាគកូនជ្រូក៖** មានកើតនៅ ស្រុកបន្ទាយស្រី(ឃុំព្រះដាក់,ឃុំត្បែង,ឃុំខ្នារសណ្តាយ) ស្រុកស្វាយលើ(ឃុំស្វាយលើ,ឃុំបឹងមាលា,ឃុំតាសៀម)បណ្តាលឲ្យជ្រូកឈឺ១០៧ក្បាលក្នុងនោះងាប់ជ្រូក១៤ក្បាល។

-**ជម្ងឺសាល់ម៉ូណែឡូ** ៖ មានកើតនៅ ស្រុកប្រាសាទបាគង(ឃុំរលួស,ឃុំបាគង,ឃុំកណ្តែក) បណ្តាលឲ្យជ្រូកឈឺ៧៧ក្បាល មិនមានងាប់ទេ ។

**សរុបជ្រូកឈឺ៣០២ក្បាល ក្នុងនោះងាប់ជ្រូក២៤ក្បាល និងជ្រូកបានសម្លាប់២ក្បាល។**

**មាន់ ៖ -ជម្ងឺអាសន្នរោគមាន់**៖មានកើត នៅស្រុកក្រឡាញ់(ឃុំស្រណាល,ឃុំកំពង់ថ្កូវ, ឃុំសំបួរ,ឃុំពោងគោ,ឃុំស្នួល) ស្រុកបន្ទាយស្រី (ឃុំព្រះដាក់) ស្រុកស្វាយលើ(ឃុំស្វាយលើ,ឃុំបឹងមាលា,ឃុំតាសៀម,ឃុំកន្ទួត,ឃុំខ្នងភ្នំ) បណ្ដាលឲ្យមាន់ឈឺ១៥៦១ចំនួនក្បាល ក្នុងនោះងាប់មាន់១២៤២ក្បាល មាន់បានសម្លាប់៥ក្បាល។

**-ជម្ងឺអុតមាន់**៖ មានកើតនៅស្រុកអង្គរជុំ(ឃុំដូនពែង,ឃុំគោកដូង,ឃុំគោល,ឃុំនគរភាស,ឃុំស្រែខ្វាវ,ឃុំតាសោម) បណ្ដាលឲ្យមាន់ឈឺ៥៤២ក្បាល ក្នុងនោះងាប់មាន់២០៦ក្បាល។

**-ជម្ងឺញ៉ូវកាសមាន់**៖មានកើត នៅស្រុកបន្ទាយស្រី (ឃុំរំចេក ,ឃុំត្បែង) ស្រុកអង្គរជុំ(ឃុំចារឈូក,ឃុំគោកដូង,ឃុំគោល,ឃុំនគរភាស,ឃុំស្រែខ្វាវ,ឃុំតាសោម)ស្រុកក្រឡាញ់(ឃុំកំពង់ថ្កូវ, ឃុំតាអាន,ឃុំចន្លាស-ដៃ,ឃុំស្នួល)បណ្ដាលឲ្យមាន់ឈឺ៩៥១ចំនួនក្បាល ក្នុងនោះងាប់មាន់៤៨០ក្បាល មាន់បានសម្លាប់២៥ក្បាល។

**សរុបមាន់ឈឺ៣០៥៤ក្បាល ក្នុងនោះងាប់មាន់១៩២៨ក្បាល និងមាន់បានសម្លាបរ៣០ក្បាល។**

**ខ. ការព្យាបាលសត្វ**

គោ៥៦៣ក្បាល ក្របី៨១ក្បាល ជ្រូក២១៧៦ ក្បាល ឆ្កែ៥២ ក្បាលមាន់២៧៥៨ ក្បាលទា២៨៨ ក្បាលទាកាប៉ា២១១ក្បាល ។

**គ. ការចាក់ថ្នាំការពារជំងឺឆ្លង ៖** អនុវត្តបាន៖

-គោសុរប៤៧.៣៦៤ក្បាល ក្នុងនោះ ការពារជំងឺសារទឹក៤៣.១២៥ក្បាល អុតក្ដាម៣៣២ក្បាលនិងបូសខ្យល់ ៣.៩០៧ក្បាល។

-ក្របីសរុប២.២៤៥ក្បាល ក្នុងនោះ ការពារជំងឺសារទឹក២.២២៦ក្បាល និងអុតក្ដាម១៩ក្បាល។

-ជ្រូក២៥.៧៣៧ក្បាល ក្នុងនោះ ជម្ងឺសារទឹក៩.៤៣១ក្បាល ជម្ងឺប៉េស្ដ១០.០៣៥ក្បាល ជម្ងឺសាល់ម៉ូណែឡូ ៦០២ក្បាល ជម្ងឺអូហ្សេស្គី ៥៤១ក្បាល ជម្ងឺរាគកូនជ្រូក២.១០៧ក្បាល ជម្ងឺកញ្ជ្រិលជ្រូក៧៦ក្បាល ជាតិដែកជ្រូក២.៨៩៣ក្បាលនិងជម្ងឺផ្លូវដងហើម៥២ក្បាល។

-មាន់សរុប៦២.៥៣២ក្បាលក្នុងនោះជម្ងឺញ៉ូវកាស២៦៦៥៤ក្បាល អាសន្នរោគ ៣០៩៤៤ក្បាល និងជម្ងឺអុត ៤.៩៣៤ក្បាល ។

-ការពារជម្ងឺប៉េស្ដទា៣៤.១៥០ក្បាល និងជម្ងឺអាសន្នរោគទា៤៩ក្បាល ។

**ឃ.ការធ្វើជីវសុវត្ថិភាព ៖** បានបាញ់ថ្នាំរំងាប់មេរោគដោយប្រើថ្នាំ*Th4* , បាចកំបោរសះ

-កន្លែងចិញ្ចឹម ៖ ចិញ្ចឹមគោ៤១កន្លែ, ចិញ្ចឹមក្របី១កន្លែង, ចិញ្ចឹមជ្រូក១០២កន្លែង, ចិញ្ចឹមមាន់១១១៩កន្លែង

-ទីផ្សារ ៖ កន្លែងពិឃាតមាន់១កន្លែង, កន្លែងលក់មាន់១កន្លែង

-តាមភូមិដ្ឋាន៖ទ្រុងចិញ្ចឹម១៤៥កន្លែង,បរិវេណភូមិ២៨កន្លែង,បរិវេណភូមិ២៨កន្លែង, សត្តឃាត្តដ្ឋាន១កន្លែង

- សត្តឃាតដ្ឋាន៖ ១០កន្លែង

- កន្លែងផ្ទុះជម្ងឺ ៖ ១០០កន្លែង

**ង. ការងារត្រួតពិនិត្យ និងទប់ស្កាត់ជម្ងឺផ្ដាសាយបក្សី**

បសុពេទ្យតាមបណ្ដាស្រុកបានចុះពង្រឹងការងារភ្នាក់ងារសុខភាពសត្វភូមិលើការតាមដាន និងទប់ស្កាត់ជម្ងឺផ្ដាសាយបក្សីជាប្រចាំ។

**៤.ការងារបណ្ដុះបណ្ដាលភ្នាក់ងារសុខភាពសត្វភូមិ និងកសិករ**

-បណ្ដុះបណ្ដាលអំពីការចិញ្ចឹមមាន់ដល់កសិករនៅភូមិត្បែងលិច ឃុំត្បែង ស្រុកបន្ទាយស្រី ចំនួន៤២នាក់ (ស្រី១៦នាក់) ។

-បណ្ដុះបណ្ដាលអំពីកបច្ចេកទេសចិញ្ចឹមមាន់ ក្រុមយុវជនរបស់អង្គការវើរសិន នៅភូមិសសរស្ដម្ភ ឃុំសសរ-ស្ដម្ភ ស្រុកពួក ២៦នាក់(ស្រី១៥នាក់) ។

-បណ្តុះបណ្តាលអំពីកបច្ចេកទេសចិញ្ចឹមមាន់ដល់កសិករ របស់អង្គការវើរីសិន នៅភូមិក្រឡាញ់ ឃុំក្រឡាញ់ ស្រុកក្រឡាញ់ (២៩នាក់(ស្រី១៦នាក់)។

-បណ្តុះបណ្តាលបន្ថែមដល់ភ្នាក់ងារសុខភាពសត្វភូមិស្រុកស្វាយលើ ចំនួន២៤នាក់(ស្រី៥នាក់) សហការជាមួយអង្គការអែហ្សអេច។

-បណ្តុះបណ្តាលអំពីកបច្ចេកទេសចិញ្ចឹមជ្រូករបស់អង្គការវើលវីសិននៅភូមិសសរស្តម្ភ ឃុំសសរស្តម្ភ ស្រុកពួក ៣៤នាក់(ស្រី២៩នាក់)។

-បណ្តុះបណ្តាលអំពីកបច្ចេកទេសចិញ្ចឹមមាន់របស់អង្គការការិតាស នៅភូមិត្រពាំងព្រីង ឃុំត្រីញ័រ ស្រុកពួក ១៥នាក់(ស្រី១៣នាក់)។

## VI. ការងារអភិវឌ្ឍន៍សហគមន៍កសិកម្ម

### ១ ការចូលរួមសិក្ខាសាលា

-បានចូលរួមសិក្ខាសាលាមួយស្តីពីវេទិកាបណ្តាញធុរកិច្ច របស់សហគមន៍កសិកម្មជាមួយវិស័យជាមួយវិស័យឯកជន ដែលសិក្ខាសាលានេះរៀបចំដោយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម និងមានការឧបត្ថម្ភគាំទ្រពីវិទ្យាស្ថានសន្តិភាពកូរ៉េ។ សិក្ខាសាលាប្រព្រឹត្តិទៅនៅភូមិកន្ទ្រក ឃុំស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានអ្នកចូលរួមចំនួន ៥៦នាក់, ស្រី២០នាក់ ជាប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម ក្នុងខេត្តសៀមរាប និងមកពីខេត្តបន្ទាយមានជ័យ ក្នុងនោះដែរ ក៏មានតំណាងក្រុមហ៊ុនជីគីមីពីប្រទេសកូរ៉េ និងក្រុមហ៊ុនអ្នកផ្គត់ផ្គង់អង្ករកម្ពុជាក៏បានចូលរួមក្នុងឱកាសនោះដែរ។

-បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីសេចក្តីព្រាងយុទ្ធសាស្ត្រនៃកម្មវិធីខ្នាតតូចនៃកម្ពុជាក្រោមការឧបត្ថម្ភរបស់អង្គការ (UNDP)។ សិក្ខាសាលានេះប្រព្រឹត្តទៅនៅសណ្ឋាគារសោមាទេវី ក្រុងសៀមរាប ខេត្តសៀមរាប។ សមាសភាពអ្នកចូលរួមសរុប ៧០នាក់, ស្រី ៦នាក់។

-ជួបពិភាក្សាជាមួយប្រតិភូស្រាវជ្រាវការផលិតស្រូវសរីរាង្គ សម្រាប់ផលិតអង្ករនាំចេញក្រៅប្រទេស។ ប្រតិភូមានសមាជិកចំនួន ០៤រូប គឺៈ មកពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជនបទកម្ពុជា ចំនួន ០១រូប, មកពីក្រុមហ៊ុនបាយ័នហើរីថេហ្គ ចំនួន០១រូប, មកពីអង្គការពេទ្យសត្វ និងក្សេត្រវិទូ ចំនួន ១រូបនិងមកពីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ចំនួន០១រូប។ ក្រោយពីពិភាក្សាគ្នាកំណត់គោលដៅរួចមក ប្រតិភូបានចុះទៅសិក្សាផ្ទាល់នៅសហគមន៍ចំនួន០៣គឺៈ១.សហគមន៍កសិកម្មទំនប់ម្កាក់អភិវឌ្ឍន៍ថ្មី នៅក្នុងឃុំគោកធ្លកលើ ស្រុកជីក្រែង, ២.សហគមន៍កសិកម្មពពេលជោគជ័យ នៅក្នុងឃុំពពេល ស្រុកសូទ្រនិគម និង ៣.សហគមន៍កសិកម្មប្រាំប្អូននាងនួនចាន់ស នៅក្នុងឃុំចាន់ស ស្រុកសូទ្រនិគម។ នៅពេលពិនិត្យស្ថានភាពជាក់ស្តែងប្រតិភូបានវាយតម្លៃថាៈ សហគមន៍ទាំង ០៣ នេះ ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផលិតស្រូវសរីរាង្គបានទេ។

-ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម ចូលរួមសិក្ខាសាលាអន្តរជាតិមួយស្តីពីការអភិវឌ្ឍសហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជា រយៈពេល៣ថ្ងៃ នៅសាលប្រជុំនៃមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េCKCC។សិក្ខាសាលានេះរៀបចំឡើងដោយ ទីភ្នាក់ងារលើកកម្ពស់ការវិនិយោគពាណិជ្ជកម្មកូរ៉េ, នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម ក្នុងគោលបំណងបង្កើននូវសហប្រតិបត្តិការរវាងសហគមន៍កសិកម្មជាមួយនឹងវិស័យឯកជន, ស្ថាប័នហិរញ្ញវត្ថុ ព្រមទាំងអង្គការអន្តរជាតិនានា។ ចូលរួមក្នុងសិក្ខាសាលានេះ មានៈ តំណាងសហគមន៍កសិកម្មមកពីខេត្តទាំង ២៥ ក្នុងទូទាំងប្រទេស, អង្គការជាតិ និងអន្តរជាតិ, ក្រុមហ៊ុនឯកជនក្នុងប្រទេស និងអន្តរជាតិ ដែលមកពីប្រទេសកូរ៉េ។

-ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម ចូលរួមសិក្ខាសាលាស្តីពីការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិនៅអគ្គនាយកដ្ឋានកសិកម្មរយៈពេល០១ថ្ងៃ។ សិក្ខាសាលានេះ មានគោលបំណងផ្សព្វផ្សាយ និងចែកចាយប្រកាសស្តីពីលក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម, សហភាពសហគមន៍កសិកម្ម និង សម្ព័ន្ធសហគមន៍កសិកម្ម ដល់មន្ទីរកសិកម្មរាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធទាំងអស់សម្រាប់យកទៅប្រើប្រាស់ក្នុង ការអភិវឌ្ឍសហគមន៍កសិកម្មរបស់ខ្លួន ។

-ចូលរួមសិក្ខាសាលាបញ្ចប់គម្រោងការចុះបញ្ជី និងពង្រឹងសមត្ថភាពសហគមន៍កសិកម្មនៅកម្ពុជា នៅសណ្ឋាគារស្ទឹងសង្កែ ខេត្តបាត់ដំបងរយៈពេល២ថ្ងៃ ដែលរៀបចំឡើងដោយអគ្គនាយដ្ឋានកសិកម្ម។នៅក្នុងគម្រោងនេះ អនុវត្តនៅខេត្តគោលដៅចំនួន ០៨ គឺ ខេត្តកំពង់ធំ, បាត់ដំបង, ពោធិសាត់,ព្រៃវែង, ស្វាយរៀង, តាកែវ, កំពត និងខេត្តកណ្តាល។ គម្រោងបានបង្កើតសហគមន៍កសិកម្មបានចំនួន៤០ និងបានផ្តល់ថវិកាចំនួន ៥០០ដុល្លារក្នុងមួយសហគមន៍។ ក្នុងនោះគម្រោងបានបណ្តុះបណ្តាលដល់សហគមន៍នូវបច្ចេកទេសមួយចំនួនដូចជា៖ ការដឹកនាំ និងរដ្ឋបាល, ការងារគណនេយ្យ,ផែនការជំនួញ,ការងារផេណទាន ,សាលារៀនស្រែកសិករ,ការធ្វើបង្ហាញដំណាំស្រូវ,បង្ហាញដំណាំបន្លែ,បង្ហាញចិញ្ចឹមមាន់ និងជ្រូក។ គម្រោងក៏បានផ្តល់សហគមន៍ដែលមានដីផ្ទាល់ខ្លួននូវឃ្លាំង១ និងឡសំងួត ១ សរុប ឃ្លាំងចំនួន២០ និងឡសំងួតចំនួន២០ ត្រូវបានផ្តល់ឱ្យសហគមន៍កសិកម្ម។

-ចូលរួមវេទិកាអាជីវកម្មរបស់សហគមន៍កសិកម្ម នៅក្នុងខេត្តចំនួន០៤ ចូលរួមគឺ ខេត្តសៀមរាប, បន្ទាយ មានជ័យ, បាត់ដំបង និងខេត្តព្រះវិហារ នៅសណ្ឋាគារខេមរា១ ខេត្តបាត់ដំបង រយៈពេល២ថ្ងៃ ដែលរៀបចំដោយអង្គការទស្សនពិភពលោក។ ក្នុងវេទិកានេះមានអ្នកចូលរួមជា៖ ថ្នាក់ដឹកនាំការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មខេត្តទាំង ៤, អភិបាលស្រុកដែលមានសហគមន៍កសិកម្មរបស់អង្គការទស្សនពិភពលោក,ប្រធានសហគមន៍កសិកម្មមកពីខេត្តក្នុងគម្រោង, និងអង្គភាពពាក់ព័ន្ធជាច្រើនទៀត។ កម្មវិធីក្នុងវេទិកានេះ មាន៖ បូកសរុបការងារសហគមន៍ឆ្នាំ២០១៥, កំណត់យុទ្ធសាស្ត្រសម្រាប់ឆ្នាំក្រោយ, ពង្រីកដៃ គូរជាមួយក្រុមហ៊ុនឯកជន, ការសហការសហគមន៍ជាមួយសហគមន៍។ ចុងបញ្ចប់ អង្គវេទិកាបានចែករង្វាន់ដល់សហគមន៍ចំនួន១២ មានស្នាដៃល្អ ក្នុងការអនុវត្តការងារសម្រាប់ឆ្នាំ ២០១៥ កន្លងមក ។

## ២.ការងារសហគមន៍កសិកម្ម

### ២.១.ការផ្សព្វផ្សាយគោលគំនិតសហគមន៍កសិកម្ម

-សហការជាមួយអង្គការយូរីដូ, ផ្សព្វផ្សាយពីគោលគំនិតសហគមន៍កសិកម្ម និងច្បាប់ស្តីពីសហគមន៍កសិកម្មដល់ក្រុមជួយខ្លួនឯងនៅក្នុងឃុំឫស្សីលក និងឃុំសង្វើយ ក្នុងស្រុកជីក្រែង ក្នុងគោលបំណងបង្កើតជាសហគមន៍កសិកម្មមួយនៅក្នុងឃុំទាំងពីរនេះ។ ក្នុងការផ្សព្វផ្សាយនេះ មានអ្នកចូលរួមចំនួន ៧៨នាក់ ស្រី ៦៩នាក់ ។

-សហការជាមួយអង្គការរចនាស្ត្រី ផ្សព្វផ្សាយពីគោលគំនិត និងច្បាប់ស្តីពីសហគមន៍កសិកម្ម ដល់ក្រុមជួយខ្លួនឯងនៅក្នុងឃុំជ្រោយនាងងួន មានអ្នកចូលរួមចំនួន ៩៨នាក់ ស្រី ៦៨នាក់ និងឃុំត្រាំសសរ ស្រុកស្រីស្នំ ដែលមានអ្នកចូលរួមចំនួន ១៦៨នាក់ ស្រី១២០នាក់។

-សហការជាមួយអង្គការការីតាស ផ្សព្វផ្សាយពីគោលគំនិត និងច្បាប់ស្តីពីសហគមន៍កសិកម្ម ដល់ក្រុមជួយខ្លួនឯងនៅក្នុងឃុំរើល ស្រុកពួក មានអ្នកចូលរួមចំនួន៥១នាក់,ស្រី ៤១នាក់ និងនៅឃុំគោកដូង ស្រុកអង្គរជុំ មានអ្នកចូលរួមចំនួន៤២នាក់ ស្រី៣៦នាក់។

-ផ្សព្វផ្សាយពីគោលគំនិត និងនិតិវិធីនៃការបង្កើតសហគមន៍កសិកម្ម ដល់មន្ត្រីនៃអង្គការសមាគមទ្រទ្រង់សហគមន៍ចំនួន៩នាក់ ស្រី០១នាក់ ។ សហការជាមួយអង្គការសមាគមទ្រទ្រង់សហគមន៍ ចុះផ្សព្វផ្សាយពីគោលគំនិត និងនិតិវិធីនៃការបង្កើតសហគមន៍កសិកម្ម,ច្បាប់ស្តីពីសហគមន៍កសិកម្ម, លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្ម បានចំនួន ៣លើក (៣ថ្ងៃ) ដល់កសិករជាសមាជិកក្រុមសន្សំប្រាក់ចំនួន២ឃុំ គឺ៖

-ឃុំតាយ៉ែក ស្រុកសូទ្រនិគម មានចំនួន៩ភូមិ មានកសិករចូលរួម ចំនួន ៩២នាក់, ស្រីចំនួន ២៩នាក់។

-ឃុំឫស្សីលក ស្រុកជីក្រែង មានចំនួន៤ភូមិ មានកសិករចូលរួមចំនួន ៤០នាក់, ស្រីចំនួន ១៩នាក់។

**២.២ ការរៀបចំមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម**

-ក្នុងឆមាសទី១ ដើមឆ្នាំ២០១៦នេះ សហគមន៍កសិកម្មដែលបានបើកមហាសន្និបាតរួចហើយមានចំនួន ២១ នៅសល់សហគមន៍ចំនួន១២ទៀត ដែលមិនទាន់បានបើកមហាសន្និបាតរបស់ខ្លួននៅឡើយ ព្រោះសុទ្ធសឹងជាសហគមន៍ទើបនឹងបង្កើតថ្មី មិនទាន់បានរយៈពេលមួយឆ្នាំ។ ក្នុងមហាសន្និបាតប្រចាំឆ្នាំនេះ សហគមន៍ទាំងអស់បានស្វែងយល់ពីភាពរីកចម្រើនរបស់ខ្លួន និងបានស្វែងរកនូវចំណុចខ្វះខាតមួយចំនួនដែលត្រូវកែលម្អ។ ក្នុងនោះដែរ សហគមន៍មួយចំនួនក៏បានធ្វើការដោះដូរ និងបោះឆ្នោតបំពេញបន្ថែមនូវសមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យសហគមន៍របស់ខ្លួន ដើម្បីឱ្យសកម្មភាពការងាររបស់សហគមន៍កសិកម្មនាឆ្នាំថ្មីនេះ មានភាពល្អប្រសើរ ជាទំនុកចិត្តរបស់សមាជិកសហគមន៍ទាំងមូល។

**២.៣ មហាសន្និបាតសហគមន៍កសិកម្មកំណើតដំបូង**

ក្នុងឆមាសទី១ ឆ្នាំ២០១៦នេះការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មនៃមន្ទីរកសិកម្មខេត្ត បានសហការជាមួយអង្គការដៃគូមួយចំនួន រៀបចំមហាសន្និបាតសហគមន៍កសិកម្មកំណើតដំបូងបានចំនួន០៤សហគមន៍ គឺ៖

១.សហការជាមួយអង្គការយូវីជូរៀបចំបើកមហាសន្និបាតសហគមន៍កសិកម្មកំណើតដំបូងនៅក្នុងឃុំឫស្សីលក ស្រុកជីក្រែង ខេត្តសៀមរាប។ មហាសន្និបាតនេះមានអ្នកចូលរួមចំនួន៥៩នាក់ ស្រី៥២នាក់ដែលមកពី២ឃុំ គឺឃុំឫស្សីលក និងឃុំសង្វើយ។ សហគមន៍មានឈ្មោះ «សហគមន៍កសិកម្មស្ត្រីភោគផលមានជ័យ» ដែលមានទីតាំងនៅក្នុងឃុំឫស្សីលក ស្រុកជីក្រែង។ បានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលសហគមន៍ចំនួន ០៧នាក់ ស្រី០៧នាក់ និងគណៈកម្មាធិការត្រួតពិនិត្យចំនួន៣នាក់ ស្រី ០៣នាក់។ ក្នុងមហាសន្និបាតនេះ បានកំណត់តម្លៃភាគហ៊ុនចំនួន ៥០.០០០៛០០ក្នុងមួយហ៊ុន ប្រាក់សមាជិកភាពចំនួន១០.០០០៛០០ក្នុងសមាជិកម្នាក់ និងបានកំណត់នូវមុខរបរសហគមន៍ចំនួន ០៤ គឺ ការងារឥណទាន, អាជីវកម្មទិញ-លក់ស្រូវ, ជីគីមី, ចំណីទា។

២.សហការជាមួយអង្គការរចនាស្ត្រី រៀបចំបើកមហាសន្និបាតសហគមន៍កសិកម្មកំណើតដំបូង នៅក្នុងឃុំជ្រោយនាងងួន ស្រុកស្រីស្នំ ខេត្តសៀមរាប។ មហាសន្និបាត មានអ្នកចូលរួមចំនួន ៦៤នាក់ ស្រី៥២នាក់ ។ សហគមន៍មានឈ្មោះ «សហគមន៍កសិកម្មរចនាស្ត្រីរុងរឿង» មានទីតាំងនៅក្នុងឃុំជ្រោយនាងនួន ស្រុកស្រីស្នំ ។ មហាសន្និបាត បានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលសហគមន៍ចំនួន ០៥នាក់ ស្រី០៤នាក់ និង គណកម្មាធិការត្រួតពិនិត្យចំនួន ៣នាក់ ស្រី ០៣នាក់។ មហាសន្និបាតបានកំណត់តម្លៃភាគហ៊ុនចំនួន ៥០.០០០៛០០ ក្នុងមួយហ៊ុន និងប្រាក់សមាជិកភាពចំនួន៥.០០០៛០០ក្នុងសមាជិកម្នាក់ និងបានកំណត់មុខរបរចំនួន០៤ គឺ ផលិតកម្មដំណាំស្រូវ, ចិញ្ចឹមសត្វ, អាជីវកម្មទិញ-លក់សម្ភារៈកសិកម្ម និងការងារឥណទាន។

៣.សហការជាមួយអង្គការការីតាស រៀបចំបើកមហាសន្និបាតសហគមន៍កសិកម្មកំណើតដំបូងបានចំនួន ០២ឃុំ គឺនៅឃុំរើល ស្រុកពួក និងឃុំគោកដូង ស្រុកអង្គរជុំ៖

ក.មហាសន្និបាតសហគមន៍កសិកម្ម នៅឃុំរើល ស្រុកពួក អ្នកចូលរួមចំនួន ៨៨នាក់ ស្រី៦៥នាក់។ សហ-គមន៍មានឈ្មោះថា «សហគមន៍កសិកម្មសាមគ្គីរុងរឿង» មានទីតាំងនៅក្នុងឃុំរើល ស្រុកពួក។មហាសន្និបាតបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលសហគមន៍ ចំនួន០៥នាក់ ស្រី០២នាក់ និងគណៈកម្មាធិការត្រួតពិនិត្យចំនួន០៣នាក់ ស្រី០៣នាក់។ មហាសន្និបាតបានកំណត់តម្លៃភាគហ៊ុនចំនួន៥០.០០០៛០០ ក្នុងមួយហ៊ុន និងប្រាក់សមាជិកភាពចំនួន៥.០០០៛០០ ក្នុងសមាជិកម្នាក់ និងបានកំណត់នូវមុខរបរសហគមន៍ចំនួន០៣ គឺការងារឥណទានខ្នាតតូច, អាជីវកម្មទិញ-លក់សម្ភារកសិកម្ម ។

ខ.រៀបចំបើកមហាសន្និបាតសហគមន៍កសិកម្មកំណើតដំបូង នៅឃុំគោកដូង ស្រុកអង្គរជុំ។ មហាសន្និបាតមានអ្នកចូលរួមមកពីឃុំនគរភាស និងឃុំគោកដូង ស្រុកអង្គរជុំ សរុបចំនួន ៩១នាក់ ស្រី៦០នាក់។ សហគមន៍មានឈ្មោះ«សហគមន៍កសិកម្មប្រជាវឌ្ឍនៈអង្គរជុំ» មានទីតាំងនៅក្នុងឃុំគោកដូង ស្រុកអង្គរជុំ។ មហាសន្និបាតបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលសហគមន៍ ចំនួន០៥នាក់ ស្រី០២នាក់ និងគណៈកម្មាធិការត្រួតពិនិត្យចំនួន០៣នាក់ស្រីគ្មាន។ មហាសន្និបាតបានកំណត់តម្លៃភាគហ៊ុនចំនួន៥០.០០០៛០០ ក្នុងមួយហ៊ុន, ប្រាក់សមាជិកភាពចំនួន ៥.០០០៛០០ ក្នុងសមាជិកម្នាក់ និងបានកំណត់នូវមុខរបរសហគមន៍ចំនួន ០៣ គឺ គឺ ការងារឥណទានខ្នាតតូច, អាជីវកម្មទិញ-លក់សម្ភារកសិកម្ម ។

៤.សហការជាមួយអង្គការសមាគមទ្រទ្រង់សហគ្រាសសហគមន៍ រៀបចំបើកមហាសន្និបាតសហគមន៍កសិកម្មកំណើតដំបូង នៅក្នុងឃុំចំនួន០២ គឺឃុំឫស្សីលក ស្រុកជីក្រែង និងឃុំតាយ៉ែក ស្រុកសូទ្រនិគមៈ

ក-មហាសន្និបាតសហគមន៍កសិកម្ម ឃុំឫស្សីលក ស្រុកជីក្រែង មានកសិករមកពី ០៤ភូមិ ចូលរួម មានចំនួន ៤១នាក់, ស្រី ២០នាក់។ សហគមន៍ថ្មីមានឈ្មោះថា «សហគមន៍កសិកម្មដៃគូរអភិវឌ្ឍន៍ឃុំឫស្សីលក»មានទីតាំងនៅក្នុងឃុំឫស្សីលក ស្រុកជីក្រែង ។ មហាសន្និបាតបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលសហគមន៍ ចំនួន០៥ នាក់ ស្រី០៣នាក់ និងគណៈកម្មាធិការត្រួតពិនិត្យចំនួន០៣នាក់ ស្រី ០៣នាក់។ មហាសន្និបាតបានកំណត់តម្លៃក្នុងមួយហ៊ុនចំនួន ៥០.០០០៛០០ ប្រាក់សមាជិកភាពចំនួន៥.០០០៛០០ និងបានកំណត់នូវមុខរបរសហគមន៍ចំនួន ០៣ គឺ ការងារឥណទានខ្នាតតូច, អាជីវកម្មទិញ-លក់សម្ភារកសិកម្ម ។

ខ-មហាសន្និបាតសហគមន៍កសិកម្ម នៅឃុំតាយ៉ែក ស្រុកសូទ្រនិគមមានអ្នកចូលរួមចំនួន ៤៦នាក់, ស្រី ៤២នាក់។សហគមន៍ថ្មីមានឈ្មោះថា«សហគមន៍កសិកម្មសាមគ្គីអភិវឌ្ឍន៍ឃុំតាយ៉ែក»មានទីតាំងនៅក្នុងឃុំតាយ៉ែក ស្រុកសូទ្រនិគម ។ មហាសន្និបាតបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលសហគមន៍ ចំនួន០៩ នាក់ ស្រី០៥នាក់ និងគណៈកម្មាធិការត្រួតពិនិត្យចំនួន០៥នាក់ ស្រី ០១នាក់។ មហាសន្និបាតបានកំណត់តម្លៃក្នុងមួយហ៊ុនចំនួន ៥០.០០០៛០០ ប្រាក់សមាជិកភាពចំនួន៥.០០០៛០០ និងបានកំណត់នូវមុខរបរសហគមន៍ចំនួន០៣ គឺការងារឥណទានខ្នាតតូច, អាជីវកម្មទិញ-លក់សម្ភារកសិកម្ម ។

**៤. ការចុះបញ្ជីទទួលសហគមន៍កសិកម្ម**

ក្នុងឆមាសទី១ ដើមឆ្នាំ២០១៦នេះ ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម បានទទួលឯកសារក្នុងសំណើរសុំចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីមន្ទីរកសិកម្មខេត្តសៀមរាប នូវសហគមន៍កសិកម្មដែលបានបើកមហាសន្និបាតកំណើតដំបូងរបស់ខ្លួនរួចរាល់ជាស្ថាពរហើយមាន០៦សហគមន៍ ដែលមន្ទីរកសិកម្មខេត្តចេញជាវិញ្ញាបនបត្រទទួលស្គាល់ជាផ្លូវការ គឺ ៖

១-សហគមន៍កសិកម្មពពេលជោគជ័យ នៅក្នុងឃុំពពេល ស្រុកសូទ្រនិគម

២-សហគមន៍កសិកម្មកុកពង្រសាមគ្គីសែនជ័យ នៅក្នុងឃុំនគរភាស ស្រុកអង្គរជុំ

៣-សហគមន៍កសិកម្មសក្តារុងរឿង នៅក្នុងឃុំបឹងមាលា ស្រុកស្វាយលើ

៤-សហគមន៍កសិកម្មប្រាសាទសាមគ្គី នៅក្នុងឃុំប្រាសាទ ស្រុកវ៉ារិន

៥-សហគមន៍កសិកម្មមោងខាងជើងសាមគ្គីជោគជ័យ នៅក្នុងឃុំមោង ស្រុកស្រីស្នំ

៦-សហគមន៍កសិកម្មនគរភាសរមៀតសំបួរជោគជ័យ នៅក្នុងឃុំនគរភាស ស្រុកអង្គរជុំ

គិតមកទល់បច្ចុប្បន្ននេះ សហគមន៍កសិកម្មដែលបានទទួលវិញ្ញាបនបត្រទទួលស្គាល់ ជាផ្លូវការពីមន្ទីរកសិកម្មខេត្តសៀមរាប មានចំនួន ៣៣សហគមន៍ គឺៈ

| ល.រ | ស្រុក/ក្រុង | អង្គការដៃគូ ក្នុងការបង្កើតសហគមន៍កសិកម្ម | | | | | | | | ចំនួនសហគមន៍កសិកម្ម |
|---|---|---|---|---|---|---|---|---|---|---|
| | | មន្ទីរកសិកម្មខេត្ត | អង្គការពុទ្ធសាសនា | អង្គការអាដា-វីដា | ទស្សនៈពិភពលោក | កែប្រែសហគមន៍ | អង្គការប៉ាដិក | គម្រោងបឹងទន្លេសាប | អង្គការ GIZ | |
| ១ | ប្រាសាទបាគង | ៣ | ១ | ២ | - | - | - | - | - | ៦ |
| ២ | ពួក | ២ | ១ | ១ | - | ១ | - | - | ១ | ៦ |
| ៣ | បន្ទាយស្រី | - | ១ | ១ | - | - | - | ១ | - | ៣ |
| ៤ | ជីក្រែង | - | - | ៣ | ២ | - | - | ១ | - | ៦ |
| ៥ | សូទ្រនិគម | ១ | - | ២ | - | - | - | ១ | - | ៤ |
| ៦ | សៀមរាប | - | - | ១ | - | - | - | - | - | ១ |
| ៧ | ក្រឡាញ់ | - | - | - | - | - | - | ១ | - | ១ |
| ៨ | អង្គរធំ | - | - | ១ | - | - | - | - | - | ១ |
| ៩ | អង្គរជុំ | - | - | - | - | - | ១ | ១ | - | ២ |
| ១០ | ស្រីស្នំ | - | - | - | - | - | - | ១ | - | ១ |
| ១១ | វ៉ារិន | - | - | - | - | - | - | ១ | - | ១ |
| ១២ | ស្វាយលើ | - | - | - | - | - | - | ១ | - | ១ |
| | **សរុប** | ៦ | ៣ | ១១ | ២ | ១ | ១ | ៨ | ១ | ៣៣ |

## VII. ការងារគ្រឿងយន្តកសិកម្ម

### ១. តាមដានពិនិត្យការភ្ជួររាស់ដោយគ្រឿងយន្តកសិកម្ម

ការងារភ្ជួររាស់ដីបង្កបង្កើនផលស្រូវវស្សាគិតត្រឹមថ្ងៃទី២១ ខែមិថុនាឆ្នាំ២០១៦ភ្ជួរបានសរុប ១១៣.០៥០ ហិកតា ក្នុងនោះភ្ជួរដោយគ្រឿងយន្តកសិកម្ម១០៥.០៦៥ ហិកតា។

### ២.ការជំរឿនស្ថិតិគ្រឿងយន្តកសិកម្មឆ្នាំ២០១៦-២០១៧

-ក្នុងឆ្នាំ២០១៦នេះយើងសង្កេតឃើញថាការភ្ជួររាស់ដីមានតម្លៃថោកជាងបណ្តាឆ្នាំមុនៗ។ កត្តាទាំង នេះមកពីតម្លៃប្រេងចុះថោកជាងឆ្នាំមុន ហើយម៉្យាងវិញទៀតគ្រឿងយន្តកសិកម្មក៏កាន់តែកើនជាងមុនដែរ ក្នុងនោះការភ្ជួរដោយគោយន្ត១ហិកតា តម្លៃពី១៤ទៅ១៥ម៉ឺនរៀល និងភ្ជួរដោយត្រាក់ទ័រតម្លៃ ១៤ ទៅ១៦ម៉ឺនរៀលក្នុង១ហិកតា។ ដោយឡែកការច្រូតកាត់ស្រូវប្រាំង ដោយម៉ាស៊ីនច្រូតស្រូវស្វ័យប្រវត្តិ(កុំបែ)ក្នុង១ហិកតា ពី២២ម៉ឺនទៅ២៥ម៉ឺនរៀល ។

-បានរៀបចំតារាងស្ថិតិគ្រឿងយន្តកសិកម្ម ដើម្បីចុះជំរឿនគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម តាមស្រុកក្រុងទាំង១២ក្នុងខេត្តសម្រាប់ ឆ្នាំ២០១៦-២០១៧។

៣.ការចុះត្រួតពិនិត្យការបំផ្លាញដោយដង្កូវហ្វូងលើដំណាំសណ្តែកបាយនៅស្រុកបន្ទាយស្រី

-ការចុះត្រួតពិនិត្យការបំផ្លាញដោយដង្កូវហ្វូងលើដំណាំសណ្តែកបាយ នៅស្រុកបន្ទាយស្រីឃើញថាដំណាំ សណ្តែកបាយទទួលរងការប៉ះពាល់មួយចំនួន ជាពិសេសសណ្តែកដែលទើបដុះបាន៧ ទៅ១០ថ្ងៃ ដោយសារដើមសណ្តែ

កនៅខ្ញី តែបើមានភ្លៀងធ្លាក់ទាន់ពេលវេលា ការបំផ្លាញនឹងមានការថយចុះ។ ក្រុមការងារបានណែនាំកសិករលើៈ .ពីការបាញ់ថ្នាំ និងសុវត្ថិភាពពេលបាញ់ថ្នាំ

.ចែកខិតប័នណែនាំពីវដ្តជីវិតនិងការបំផ្លាញរបស់ដង្កូវហ្វូង

.ពិនិត្យឧបករណ៍ដាំសណ្តែកបាយបំពាក់ដោយគ្រឿងយន្ត

.ពិនិត្យការកែច្នៃឧបករណ៍បាញ់ថ្នាំដោយប្រើម៉ាស៊ីនបាញ់ខ្យល់ ភ្ជាប់ជាមួយក្បាលគោយន្ត ដែលអាចបាញ់បាន១ដង២៥ម៉ែត្រ។

**៣សហការជាមួយគម្រោងកាត់បន្ថយភាពក្រីក្រ និ.ងអភិវឌ្ឍន៍កសិកម្មខ្នាតតូច តំបន់ទន្លេសាប**

បានសហការជាមួយគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប ដោយបានចុះអនុវត្តនៅក្នុងស្រុកគោលដៅដែលមានសកម្មភាព ចុះបង្រៀនបច្ចេកទេសដាំបន្លែ និងការអនុវត្តកសិកម្មល្អដល់កសិករ ដូចជា ការរៀបចំដី ការដាក់ជីទ្រាប់បាត ការដាំ(ចន្លោះគុម្ព និងជួរ) ការថែទាំ ការប្រមូលផល និងការវិភាគចំណូលចំណាយ ជាដើម។

## VIII. ការងារកសិ-ឧស្សាហកម្ម

**១.សកម្មភាពការងារ**

-ថ្ងៃទី២៣-២៥.១២.២០១៥ មន្ត្រីការិយាល័យ ០១រូប បានចូលរួមសិក្ខាសាលា ស្តីពីការវិភាគរកវត្ថុមាន និងតាមដានរកវត្ថុមានសារពាង្គកាយកែច្នៃរស់នៅសណ្ឋាគារអង្គរប៉ារ៉ាឌីខេត្តសៀមរាប។

-ថ្ងៃទី០២.០២.២០១៦ មន្ត្រីការិយាល័យ ០២រូប បានចូលរួមសិក្ខាសាលា ស្តីពីផែនការលម្អិតឆ្នាំ២០១៦របស់គម្រោងតំបន់ទន្លេសាប នៅសណ្ឋាគារអង្គរប៉ារ៉ាឌីខេត្តសៀមរាប។

-ថ្ងៃទី០២-០៤.០២.២០១៦ មន្ត្រីការិយាល័យ ០១រូប សហការជាមួយនាយកដ្ឋាន បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់ស្តង់ដារគុណភាព សុវត្ថិភាពនៃផលិតផលកសិកម្ម នៅស្រុកចំនួន ៣ ដែលមានអ្នកចូលរួមចំនួន១៩២នាក់ ស្រី១៥០នាក់ ។

**២.ស្ថិតិដំណាំកសិ-ឧស្សាហកម្ម**

**ការិយាល័យបានសហការជាមួយកសិកម្មស្រុកប្រាសាទបាគង ស្វាយលើ វ៉ារិននិងស្រុកបន្ទាយស្រី ស្រង់ស្ថិតិដំណាំម្រេច ដែលបានដាំដុះក្នុងស្រុកបានលទ្ធផលដូចខាងក្រោម ៖**

| ល.រ | ឈ្មោះស្រុក | ផ្ទៃដីដាំដុះ(ហ.ត) | ផ្ទៃដីប្រមូល(ហ.ត) | ទិន្នផលមធ្យម (ត/ហត) |
|---|---|---|---|---|
| ១ | ប្រាសាទបាគង | ៥ | 0 | 0 |
| ២ | ស្វាយលើ | ៧០ | ៣០ | ១,៨ |
| ៣ | បន្ទាយស្រី | ៥៤ | ១០ | ២,៥ |
| ៤ | វ៉ារិន | ៦ | 0 | 0 |
| សរុប | | ១៣៥ | ៤០ | ១,៩៧ |

**៣និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប សហការជាមួយគម្រោងកាត់បន្ថយភាពក្រីក្រ.**

មន្ត្រីក្នុងការិយាល័យចំនួន២នាក់កំពុងអនុវត្តគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ប្រចាំក្រុងសៀមរាប និងស្រុកសូទ្រនិគម ដែលមានលទ្ធផលដូចខាងក្រោម៖

-ចុះណែនាំបច្ចេកទេសដល់កសិករដាំដំណាំក្រោយប្រមូលផលចំនួន៤កន្លែង នៅភូមិជ្រាវ សង្កាត់ជ្រាវ និងភូមិចន្លោង សង្កាត់ស្រង៉ែ ក្រុងសៀមរាប និងភូមិបែកកាំភ្លើង ឃុំចាន់ស និងភូមិសំបាត ឃុំខ្នារពោធិ៍ ស្រុកសូទ្រនិគម។

-បណ្តុះបណ្តាលកសិករអនុវត្តកសិកម្មល្អចំនួន២សាលានៅភូមិអញ្ចាញសង្កាត់នគរធំនិងភូមិក្រសាំងសង្កាត់ជ្រាវ
-ចូលរួមប្រជុំជាមួយក្រុមកសិករកែលម្អជីវភាពតាមបណ្តាភូមិមួយចំនួន ស្តីពីដំណើរគ្រប់គ្រងទុនបង្វិលក្រុម។
-បន្តចុះគាំទ្រសកម្មភាពដល់កសិករធ្វើបង្ហាញនាឆ្នាំកន្លងមក និងអនុវត្តសកម្មភាពថ្មីសម្រាប់ឆ្នាំ២០១៦នេះ។

## IX. ការងារនីតិកម្មកសិកម្ម

### ១. ស្ថានភាពមូលដ្ឋានអាជីវកម្មសម្ភារកសិកម្ម

សរុបជារួម គិតត្រឹមធមាសទី១ ឆ្នាំ២០១៦ មូលដ្ឋានអាជីវកម្មលក់ដុំ លក់រាយជី ថ្នាំកសិកម្មរួមមាន៖

-មូលដ្ឋានអាជីវកម្មសរុប ១៧៥ ដេប៉ូ។

-មូលដ្ឋានអាជីវកម្មមានលិខិតអនុញ្ញាត ១៧៥ ដេប៉ូ។

-មូលដ្ឋានអាជីវកម្មគ្មានលិខិតអនុញ្ញាត 0ដេប៉ូ ។

### ២.ការងារអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល

ចំពោះការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលការិយាល័យ អនុវត្តនិងសម្រេចបានលទ្ធផលដូចខាងក្រោម៖

-រៀបចំ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ២១មកខ.សជណ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករលក់ដុំ លក់រាយសម្ភារកសិកម្ម ។

-បានបណ្តុះបណ្តាលចំនួន០១លើក លើប្រធានបទរួមគ្នាកាត់បន្ថយផលប៉ះពាល់នៃថ្នាំសំលាប់សត្វល្អិត ដើម្បីធានាបាននូវសុខុមាលភាពនឹងសុវត្ថិភាពម្ហូបអាហារ។

-បានបណ្តុះបណ្តាលលើប្រធានបទថ្នាំកសិកម្មនិងការប្រើប្រាស់ឲ្យមានសុវត្ថិភាពនិងប្រសិទ្ធភាពចំនួន៧លើក។

-បានចុះណែនាំអាជីវករស្តីពីការតាមដានការលក់ដុំលក់រាយសម្ភារៈកសិកម្ម នៅស្រុកក្រឡាញ់០១លើក។

-បានបណ្តុះបណ្តាលពង្រឹងផ្នែកច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ដល់អាជីវករ ស្តីពីវគ្គបំពាក់បំប៉នស្តីពីការពង្រឹងច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម សុវត្ថិភាព និងបច្ចេកទេសដាំដុះដំណាំដល់អាជីវករលក់សម្ភារកសិកម្ម ចំនួន ០១វគ្គ។

-ផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងពី ការតម្រូវបមាណីលើស្លាកសញ្ញាព័ត៍មាននៃ សំបកវេចខ្ចប់ ០១លើក។

-បានណែនាំពីវិធានសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំកសិកម្ម និងអនុវត្តផ្ទាល់ចំនួន ០១លើក។

-ការិយាល័យនីតិកម្មកសិកម្មបានសហការជាមួយនាយកដ្ឋាននីតិកម្មកសិកម្ម បើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករធ្វើអាជីវកម្មសម្ភារកសិកម្ម និងកសិករ ដំណើរការវគ្គនេះបានធ្វើឡើងនៅស្ថានីយ៍ពិសោធន៍ស្រាវជ្រាវកសិកម្មទឹកវិលដែលមានរយៈពេលសរុប០៥ថ្ងៃ មានសិក្ខាកាមសរុប៥១នាក់ ស្រី២០នាក់ លើមុខវិជ្ជាដែលមាន៨ម៉ូឌុល។

**ជារួមលទ្ធផលនៃសកម្មភាព អប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលរួមមាន៖**

-ចំនួនលើកនៃការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល ១២លើក។

-ចំនួនអ្នកចូលរួមសរុប ៣៩៨ នាក់ ក្នុងនោះជាស្ត្រី ១៩៣នាក់។

### ៣.ការងារតាមដាន ស្រាវជ្រាវនិងបង្ក្រាបបទល្មើស

-បានអនុវត្តតាមដាន ស្រាវជ្រាវករណីប្រើប្រាស់ថ្នាំពុលក្តាមនៅភូមិល្វា ឃុំល្វា ស្រុកពួក ឆ្លើយតបសំណូមពរស្នើសុំអង្គភាពជំនាញជួយអន្តរាគមន៍ទប់ស្កាត់ការប្រើប្រាស់ថ្នាំបំពុលក្តាម ដែលធ្វើអោយពុលត្រី និងប៉ះពាល់ដល់បរិស្ថាន ។

- បានចុះត្រួតពិនិត្យការតាំងលក់ជីកសិកម្ម និងថ្នាំកសិកម្ម នៅតាមមូលដ្ឋានអាជីវកម្មនៃស្រុក ពួក សូទ្រនិគម វ៉ារិន និងក្រុងសៀមរាបមានលទ្ធផលដូចខាងក្រោម៖

.ចំនួនលើកនៃការចុះត្រួតពិនិត្យ ០៧លើក។

.មូលដ្ឋានអាជីវកម្មបានចុះត្រួតពិនិត្យ ចំនួន១៨មូលដ្ឋាន។

.បានធ្វើការណែនាំផ្ទាល់មាត់ដល់មូលដ្ឋានអាជីវកម្ម ចំនួន០៨ករណី។

.បានធ្វើកំណត់ហេតុត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម ចំនួន ១១ករណី។

.លិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរកាល ០១ករណី ស្មើទឹកប្រាក់ ១.០០០.០០០រៀល( ចំពោះប្រាក់ពិន័យអាជីវករបង់ប្រាក់ជាមួយនាយកដ្ឋាននីតិកម្មកសិកម្ម)។

## X. ការខារផ្សព្វផ្សាយកសិកម្ម

**១.ការចូលរួមសិក្ខាសាលា៖** ក្នុងឆ្នាំ២០១៦នេះ មន្ត្រីក្នុងការិយាល័យបានចូលរួមសិក្ខាសាលាចំនួន ៣លើក ក្នុងនោះ៖

-ចូលរួមសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយគោលនយោបាយកសិកម្ម ដែលមានសិក្ខាកាមចូលរួមមកពីអគ្គនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម មន្ត្រីកសិកម្មខេត្ត ស្រុក នៃមន្ទីរកសិកម្ម អង្គការដែលអនុវត្តពាក់ពន្ធ័ការងារវិស័យកសិកម្មក្នុងខេត្ត សរុប ៣៥នាក់ រយៈពេល១ថ្ងៃ នៅខេត្តសៀមរាប ។

-ចូលរួមសិក្ខាសាលាបញ្ចប់គម្រោងកម្មវិធីផ្នែកសុខភាព អាហារូបត្ថម្ភ បំណិនជីវិត និងអនាម័យ ដែលអនុវត្តដោយអង្គការភ្លែន និងអង្គការដៃគូរក្រោមគម្រោងឧបត្ថម្ភស្បៀងបន្ទាន់-ហិរញ្ញប្បទានបន្ថែម មានរយៈពេល០១ថ្ងៃ នៅសណ្ឋាគារអេប្សរាអង្គរ ដែលមានអ្នកចូលរួមចំនួន ១៣៥នាក់ ស្រី៦៧ នាក់។

-ចូលរួមសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគោលការណែនាំ ស្តីពីសុខភាព សុវត្ថិភាពការងារ និងបរិស្ថានសម្រាប់ការប្រើប្រាស់ជីវឧស្ម័ន ដែលបានរៀបចំឡើងនៅសណ្ឋាគារមេនោរាជអង្គរ ដោយវិទ្យាស្ថានស្តង់ដារកម្ពុជានៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងសិក្ខាសាលាមានសមាជិកចូលរួម ២៦នាក់ ស្រី៥នាក់ ដែលមកពីមន្ទីរកសិកម្ម, មន្ទីររ៉ែនិងថាមពល, មន្ទីរពាណិជ្ជកម្ម និងមន្ទីរឧស្សាហកម្ម និងសិប្បកម្ម, រោងម៉ាស៊ីនកិនស្រូវ ដែលមកពីខេត្តសៀមរាប និងខេត្តកំពង់ចាម ។

**២.ការងារផ្សព្វផ្សាយកសិកម្ម**

-បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល(អ៊ែរី) ដែលមានទីតាំងក្នុងខេត្តសៀមរាប ដើម្បីចូលរួមចែកគ្រាប់ពូជស្រូវ ១០ពូជ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ សម្រាប់អោយកសិករយកទៅអនុវត្តស្រែដើមរដូវនិងស្រែរដូវប្រាំង ស្រែរដូវវស្សា នៅតាមស្រុកក្នុងខេត្តសៀមរាប ។

-ចុះធ្វើបច្ចុប្បភាពភ្នាក់ងារផ្សព្វផ្សាយភូមិ នៅ១១ស្រុកខេត្តសៀមរាប ដោយសហការជាមួយគ្រប់ការិយាល័យកសិកម្មស្រុក អាជ្ញាធរឃុំ ភូមិ និងភ្នាក់ងារផ្សព្វផ្សាយភូមិផ្ទាល់សរុប៨៥នាក់ និងភ្នាក់ងារផ្សព្វផ្សាយខ្លះក្លាយជាក្រុមប្រឹក្សាឃុំ មេភូមិ អនុភូមិ សមាជិកភូមិ និងភ្នាក់ងារពេទ្យសត្វភូមិ និងកសិករគំរូក្នុងមូលដ្ឋានសម្រាប់ស្ថាបនអភិវឌ្ឍន៍ផ្សេងៗ និងមួយចំនួនកសិករ ក្នុងនោះផងដែរក៏មានចំណាកស្រុកមួយចំនួន ។

-ប្រជុំមន្ត្រីការិយាល័យស្តីពីការផ្សព្វផ្សាយ និងរៀបចំផែនការបណ្តុះបណ្តាល ប្រើប្រាស់ថវិកាតាមកម្មវិធីរបស់មន្ទីរកសិកម្មខេត្តសៀមរាប១លើក ។

-ប្រជុំ២លើក ស្តីពី រៀបចំផែនការសកម្មភាពប្រើប្រាស់ថវិកាតាមកម្មវិធី សម្រាប់ឆ្នាំ២០១៥ អនុវត្តន៍ផែនការសកម្មភាពឆ្នាំ២០១៦ និង រៀបចំផែនការសកម្មភាពគម្រោងប្រើប្រាស់ថវិកាតាមកម្មវិធីសម្រាប់ឆ្នាំ២០១៧ ។

-ចូលរួមចែកគ្រាប់ពូជស្រូវធន់ទ្រាំរាំងស្ងួត និងទឹកជំនន់ (១០ពូជ) សហការជាមួយកម្មវិធីអ៊ែរី ប្រចាំខេត្តសៀមរាប ក្នុងស្រុកចំនួន ៤ សរុបអ្នកទទួលផល ៥៧៥គ្រួសារ ស្មើគ្រាប់ពូជ ២៨៧៥គីឡូក្រាម(មួយគ្រួសារទទួលបានពូជស្រូវ ៥គីឡូក្រាម) រួមមានស្រុកពួក ឃុំដូនកែវ ចំនួន ២៥០គ្រួសារ, ស្រុកអង្គរធំ ឃុំស្វាយចេក ចំនួន ៩០

គ្រួសារ ,ស្រុកបន្ទាយស្រី ២៥គ្រួសារ និងស្រុកស្រីស្នំ ៤ឃុំ ២១០គ្រួសារ គោលបំណងរបស់កម្មវិធីនេះ ដើម្បីអោយកសិករយកពូជធន់ទ្រាំរាំងស្ងួត ទឹកជំនន់ ទៅប្រើប្រាស់ផលិតជាពូជ និងទុកពូជបន្ត ។

**៣.ការបណ្តុះបណ្តាល**

-បានបញ្ជូនមន្ត្រីការិយាល័យផ្សព្វផ្សាយកសិកម្មចំនួន០២រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីផលិតកម្មគ្រាប់ពូជស្រូវ ចំនួន ០២ថ្ងៃនៅខេត្តសៀមរាប ។

-ថ្នាក់ដឹកនាំការិយាល័យផ្សព្វផ្សាយកសិកម្ម បានចូលរួមវគ្គផ្សព្វផ្សាយបច្ចេកទេសស្តីពីសត្វល្អិតនិងជំងឺលើដំណាំស្វាយ ចំនួន ០១ថ្ងៃនៅស្រុកបន្ទាយស្រី ខេត្តសៀមរាប សហការជាមួយអគ្គនាយកដ្ឋានកសិកម្ម ។

-ថ្នាក់ដឹកនាំការិយាល័យបានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការផ្ទេរបច្ចេកវិទ្យា និងផ្សព្វផ្សាយចំណេះដឹងកសិកម្ម ដែលមានសិក្ខាកាមចូលរួមមកពី ៤ខេត្ត គឺខេត្តសៀមរាប, ខេត្តបាត់ដំបង, ខេត្តពោធិ៍សាត់, ខេត្តកំពត និងបុគ្គលិកវិទ្យាស្ថានអភិវឌ្ឍន៍កសិកម្មកម្ពុជាសរុប២៥នាក់ វគ្គនេះរៀបចំនៅវិទ្យាស្ថានអភិវឌ្ឍន៍កសិកម្មកម្ពុជា រយៈពេល ៥ថ្ងៃ ។

-ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីផលិតកម្មគ្រាប់ពូជស្រូវ របស់គម្រោងស្រាវជ្រាវដំណាំស្រូវអន្តរជាតិ នៅខេត្តសៀមរាប។ វគ្គបណ្តុះបណ្តាលនេះផ្តួចផ្តើមឡើងដោយគម្រោងស្រាវជ្រាវដំណាំស្រូវអន្តរជាតិប្រចាំខេត្តសៀមរាប សិក្ខាកាមចូលរួមសរុប៥៥នាក់ មកពីមន្ទីរកសិកម្មខេត្ត ស្រុក សហគមន៍កសិកម្ម កសិករគំរូ ។

## XI. ការងារកៅស៊ូ

នៅក្នុងខេត្តមានក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ចចំនួន០៣ ដែលកំពុងមានសកម្មភាព គឺក្រុមហ៊ុនសុក័ណ្ណជាវីពាណិជ្ជខូអិលធីឌី ក្រុមហ៊ុនចំការកៅស៊ូក្រែក និងក្រុមហ៊ុន ខេនលីមីតធីត និងស្រង់ស្ថិតិការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារ។

**១.ក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ច**

**១.១ ក្រុមហ៊ុនសុក័ណ្ណជាវីពាណិជ្ជខូអិលធីឌី**

ក្រុមហ៊ុនមានផ្ទៃដីកំពុងធ្វើអាជីវកម្មចំនួន១.២៣២,២២ហិកតាក្នុងអនុតំបន់១ និង២ និងផ្ទៃដីដែលនៅសល់មិនបានដាំដុះចំនួនសរុប២៤៤,៧៣ហិកតា ត្រៀមសម្រាប់ដាំក្នុងឆ្នាំ២០១៦។ ក្នុងខែមិថុនានេះក្រុមហ៊ុនពុំមានការឈូសឆាយដីថ្មីទេ ហើយក្រុមហ៊ុនបន្តការថែទាំដំណាំស្វាយចន្ទីមានចំនួនសរុប ៩១៥,៤៧ហិកតា។

**១.២ ក្រុមហ៊ុនចំការកៅស៊ូក្រែក**

-ក្រុមហ៊ុនបានដាំដំណាំកៅស៊ូចំនួនសរុប៩៣៣ហិកតា និងដំណាំស្វាយចន្ទីមាន ចំនួនសរុប១១៦ហិកតា និងពុំមានការឈូសឆាយដាំដុះថ្មីទេ។

-ក្នុងខែមិថុនានេះ ក្រុមហ៊ុនបានធ្វើសំណើរសុំប្តូរមុខដំណាំកៅស៊ូ មកដាំស្វាយចន្ទីវិញ។

-ក្រុមហ៊ុនបានភ្ជួរចោលកូនកៅស៊ូដែលបានដាំក្នុងឆ្នាំ២០១៤ចំនួន២៧០ហ.ត ដោយសារវាពុំមានការដុះលូតលាស់បានល្អ និងផ្ទៃដីចាស់ចំនួន ១៣០ហ.ត សរុប៤០០ហ.ត ដោយបានដាំជំនួសនូវកូនស្វាយចន្ទីវិញហើយ

**១.៣ ក្រុមហ៊ុនខេនលីមីតធីត**

-ក្រុមហ៊ុនអនុវត្តន៏បន្តការថែទាំដំណាំកៅស៊ូដែលបានដាំចំនួនសរុប១.៧៩២ហិកតា និងដាំដំណាំម្រេចចំនួន ១២ហិកតា។

- ក្រុមហ៊ុនបានរៀបចំដីសម្រាប់ដាំម្រេចបានចំនួន៣ហិកតា លើផ្ទៃដីដែលដាំកៅស៊ូពុំបានល្អ។

-ក្រុមហ៊ុនបានបើកមុខសាកល្បងចៀរជ័រកៅស៊ូចំនួន៣៦៧ហិកតា ស្មើចំនួន ១០៥.៨៩០ដើម។

**២.ការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារ-ឯកជន៖** មន្ត្រីក្នុងការិយាល័យបានចុះជំរឿនបានលទ្ធផលដូចខាងក្រោម៖

-ផ្ទៃដីដាំកៅស៊ូជាលក្ខណៈគ្រួសារ-ឯកជនចំនួន០៧គ្រួសារក្នុងស្រុកបន្ទាយស្រីមានផ្ទៃដីចំនួន២២១,៥ហ.ត។
-ផ្ទៃដីដាំកៅស៊ូជាលក្ខណៈគ្រួសារ-ឯកជនចំនួន០៣គ្រួសារ ក្នុងស្រុកអង្គរធំ មានផ្ទៃដីចំនួន៧២ហ.ត។
-ផ្ទៃដីដាំកៅស៊ូជាលក្ខណៈគ្រួសារ-ឯកជនចំនួន១២គ្រួសារ ក្នុងស្រុកអង្គរជុំ មានផ្ទៃដីចំនួន៤៨០ហ.ត។

**៣.ច្បារពូជកៅស៊ូ**

នៅក្នុងខេត្តមានច្បារពូជកៅស៊ូ ១កន្លែង ស្ថិតនៅភូមិឈូកសរ ឃុំឃុនរាម ស្រុកបន្ទាយស្រី ដែលមានផ្ទៃដីសរុប ៧ហិកតា ក្នុងនោះដាំកូនកៅស៊ូពូជបាន ៥ហិកតា មាន៤ពូជ គឺពូជ FB260, RRIM600, RRIT251, RRIM712

## XII. បញ្ហាប្រឈម និងដំណោះស្រាយ

| ល.រ | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| ១ | ការធ្វើស្រែដោយភាគច្រើននៅពឹងផ្អែកទៅលើរបបទឹកភ្លៀង ខ្វះខាតប្រព័ន្ធស្រោចស្រព។ | -កែលម្អទំនប់ ប្រឡាយ អាងស្តុកទឹក, -ពង្រីកប្រព័ន្ធស្រោចស្រព។ |
| ២ | មានគ្រោះធម្មជាតិគំរាមកំហែងជារៀងរាល់ឆ្នាំ (រាំងស្ងួត ទឹកជំនន់...) ធ្វើឲ្យមានការប៉ះពាល់និងខូចខាតលើផ្ទៃដីដំណាំស្រូវ បណ្តាលឲ្យមានការប្រែប្រួលទៅលើបរិមាណផលស្រូវ ។ | -ជ្រើសរើសពូជធន់ទ្រាំ, រៀបចំផែនការដាំដុះឲ្យត្រូវរដូវ កាល(ស្រាល កណ្តាល ធ្ងន់)។ -ត្រៀមពូជស្រូវ ពូជដំណាំ សំបកការុង មធ្យោបាយ និងសម្ភារៈឧបករណ៍ផ្សេងៗទៀត ដើម្បីអន្តរាគមន៍ ជួយដល់កសិករ។ |
| ៣ | កសិករពុំទាន់មានលទ្ធភាពប្រើប្រាស់ឧបករណ៍ មធ្យោបាយផលិតកម្មកសិកម្មឲ្យបានសមស្រប ដូចជាការកែលម្អរៀបចំដីដាំដុះ ការប្រើប្រាស់ពូជ ជី ការទុកដាក់ក្រោយពេលប្រមូលផល និងការវេចខ្ចប់។ | ផ្សព្វផ្សាយ បណ្តុះបណ្តាលបច្ចេកទេសបន្ថែមកសិករតាមរយៈមធ្យោបាយនានា ដូចជាការបញ្ចុះមន្ត្រីផ្ទាល់ដល់ភូមិដ្ឋាន ធ្វើបង្ហាញ ផ្តល់ឯកសារជាសៀវភៅ ខិតប័ណ្ណ ជាដើម។ |
| ៤ | មន្ត្រីខេត្តស្រុកមួយចំនួនមានការយល់ដឹងលើការងារបច្ចេកទេសនៅមានកំរិត ។ | ស្នើសុំវគ្គបំពាក់បំប៉នមន្ត្រីបច្ចេកទេសបន្ថែមដោយវិទ្យាសាស្ត្រមានការវិវត្តន៍ពីមួយឆ្នាំទៅមួយឆ្នាំ។ |
| ៥ | ខ្វះមន្ត្រីបម្រើការងារនៅតាមបណ្តាស្រុកមួយចំនួនដែលធ្វើឲ្យការងារមានការលំបាក។ | ស្នើសុំមន្ត្រីបន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពការងារឲ្យទទួលបានលទ្ធផលល្អប្រសើរថែមទៀត។ |
| ៦ | ការប្រមូលគោក្របីមកចាក់ថ្នាំការពារនៅដើមរដូវវស្សាមានការពិបាកដោយកសិករយកគោក្របីទៅធ្វើការភ្ជួររាស់ ។ | ធ្វើការផ្សព្វផ្សាយ និងត្រៀមថ្នាំការពារឲ្យបានគ្រប់គ្រាន់សម្រាប់ចាក់ការពារជម្ងឺសត្វឲ្យបានមុនរដូវភ្លៀងធ្លាក់ជោកជាំ ។ |
| ៧ | ខ្វះមន្ត្រីជំនាញបច្ចេកទេសគ្រឿងយន្តកសិកម្ម និងគ្រឿងយន្ត ព្រមទាំងឧបករណ៍កសិកម្ម។ | សុំផ្តល់មន្ត្រីជំនាញបច្ចេកទេសគ្រឿងយន្តកសិកម្ម និង គ្រឿងយន្តព្រមទាំងឧបករណ៍កសិកម្ម ដើម្បីមានលទ្ធភាពចុះជួយអន្តរាគមន៍ និងកែលម្អដល់កសិករឲ្យប្រសើរឡើង។ |
| ៨ | ថ្នាក់ដឹកនាំសហគមន៍មួយចំនួនធំមានវ័យចាស់ជរា និងសមត្ថភាព, ចំណេះដឹងនៅមានកម្រិត។ | លើកទឹកចិត្តដល់យុវជនក្នុងមូលដ្ឋាន ដើម្បីចូលរួមក្នុងសហគមន៍កសិកម្ម។ |
| ៩ | កង្វះទុនសម្រាប់ធ្វើអាជីវកម្មផ្សេងៗធ្វើឱ្យសហគមន៍ | ស្វះស្វែងរកដៃគូអភិវឌ្ឍន៍នានា ដែលមានធន |

| | | |
|---|---|---|
| | ខ្លះត្រូវខ្ចីទុនពីធនាគារឯកជនក្នុងតម្លៃការប្រាក់ខ្ពស់ និងត្រូវដាក់ទ្រព្យបញ្ចាំ។ | ធានសម្រាប់ផ្តល់ឱ្យសហគមន៍កសិកម្មខ្ចី សម្រាប់សហគមន៍ធ្វើដើមទុនក្នុងអាជីវកម្មរបស់ខ្លួន។ |
| ១០ | -ការយល់ដឹងពីស្លាកសញ្ញាព័ត៌មានលើសំបកវេចខ្ចប់ និងការយល់ដឹងពីថ្នាំកសិកម្ម និងវិធានសុវត្ថិភាពនៅមានកម្រិត។ | - សហការជាមួយអ្នកពាក់ព័ន្ធបញ្ជ្រាបការយល់ដឹងពីស្លាកសញ្ញាព័ត៌មានលើសំបកវេចខ្ចប់និងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលបណ្តុះបណ្តាលពីថ្នាំកសិកម្ម និងការប្រើប្រាស់ដោយសុវត្ថិភាពនិងប្រសិទ្ធភាព ។ |

## XII. ទិសដៅសម្រាប់អនុវត្តឆមាសទី២ ឆ្នាំ២០១៦

| ល.រ | ទិសដៅសកម្មភាពសម្រាប់អនុវត្តបន្ត | ត្រីមាស | |
|---|---|---|---|
| | | ៣ | ៤ |
| ១ | ពង្រឹងការអនុវត្តតាមរបៀបរបបការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងលិខិត និងចាត់ចែងចរន្តលិខិតរដ្ឋបាល ការគ្រប់គ្រងមន្ត្រីតាមរយៈការចុះបញ្ជីវត្តមាន កម្មវិធីនិងគ្រប់គ្រង ការងារបណ្តុះបណ្តាលឲ្យកាន់តែមានប្រសិទ្ធភាព និងប្រសើរឡើង។ | ✓ | ✓ |
| ២ | ត្រៀមលក្ខណៈ និងជម្រុញមន្ត្រីចូលរួមបង្កើនសមត្ថភាពតាមរយៈការបណ្តុះបណ្តាល(អនុវត្តថវិកាតាមកម្មវិធី។ | ✓ | ✓ |
| ៣ | ធ្វើសំណើសុំបៀវត្សប្រចាំខែ ពិនិត្យតាមដាន ការគ្រប់គ្រងមន្ត្រី និងលើកសំណើររៀបចំ មន្ត្រីទៅតាមសភាពជាក់ ស្តែងនៃការិយាល័យនីមួយៗ និងកសិកម្មបណ្តាស្រុក-ក្រុង។ | ✓ | ✓ |
| ៤ | រៀបចំគណៈកម្មការពិនិត្យវាយតម្លៃសុំគ្រឿងឥស្សរិយយស និងតម្លើងកាំបៀវត្សប្រចាំឆ្នាំ។ | ✓ | ✓ |
| ៥ | បន្តស្រង់ស្ថិតិតម្លៃផលិតផលកសិកម្ម៤ដង/សប្តាហ៍ដែលស្រង់តម្លៃផលិតផលប្រមាណ៥០មុខប្រចាំ សប្តាហ៍(១ដង/សប្តាហ៍)និងតម្លៃលក់ដុំចំនួន៣៥មុខ(១ដង/សប្តាហ៍)ផ្ញើជូនក្រសួងនិងអង្គភាពពាក់ព័ន្ធ។ | ✓ | ✓ |
| ៦ | ជំរុញនិងសហការការិយាល័យជំនាញក្នុងមន្ទីរ ប្រមូលឯកសារ ទិន្នន័យ ដើម្បីបូកសរុបរិភាគប្រចាំឆ្នាំ និងធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៣ឆ្នាំ ៥ឆ្នាំរបស់មន្ទីរ។ | ✓ | ✓ |
| ៧ | ជំរុញលើកផែនការសកម្មភាពថវិកាតាមកម្មវិធី សម្រាប់ប្រចាំឆ្នាំ២០១៧ និងផ្សព្វផ្សាយពីនីតិវិធីនៃការអនុវត្តគម្រោងផែនការសកម្មភាពថវិកាប្រចាំឆ្នាំ២០១៦។ | ✓ | ✓ |
| ៨ | ជំរុញការងារបង្កបង្កើនផលរដូវវស្សាឲ្យបានទាន់រដូវកាល និងគ្រប់តាមផែនការដែលបានដាក់ចុះ។ | ✓ | ✓ |
| ៩ | ជំរុញការជួសជុលទំនប់ និងបិទភ្លឺស្រែឲ្យបានធំមាំ ដើម្បីរក្សាទឹកទុកក្នុងស្រែពេលជួបភាពរាំងស្ងួត។ | ✓ | ✓ |
| ១០ | បន្តផ្សព្វផ្សាយធ្វើស្រែដោយប្រើពូជស្រូវ១០ពូជ ដល់កសិករនៅតាមមូលដ្ឋាន និងជំរុញការធ្វើស្រែបង្ហាញ។ | ✓ | ✓ |
| ១១ | ចាត់មន្ត្រីចុះតាមដានកត្តាចង្រៃលើដំណាំតាមបណ្តាមូលដ្ឋាននានាដើម្បីអន្តរាគមន៍ទាន់ពេលវេលា | ✓ | ✓ |
| ១២ | ចាក់ថ្នាំការពារជម្ងឺគោក្របី ចំនួន៣០.០០០កំរិតតាមបណ្តាស្រុក។ | ✓ | ✓ |
| ១៣ | តាមដានសុខភាពសត្វ អន្តរាគមន៍ពេលផ្ទុះជម្ងឺសត្វ ។ | ✓ | ✓ |
| ១៤ | ត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលមានដើមកំណើតពីសត្វ ។ | ✓ | ✓ |
| ១៥ | សាងសង់ឡជីវឧស្ម័នចំនួន២៦ឡ។ | ✓ | ✓ |

| | | | |
|---|---|---|---|
| ១៦ | ជំរុញ និងត្រួតពិនិត្យពីសកម្មភាពការងាររបស់សហគមន៍កសិកម្មដែលបានបង្កើតហើយ ទាំងការគ្រប់គ្រងដឹកនាំ និងការងារថវិកា។ | ✓ | ✓ |
| ១៧ | បង្កើនការសហការជាមួយអង្គការក្នុងខេត្តសៀមរាបដើម្បីពង្រឹងសកម្មភាពសហគមន៍កសិកម្ម និងការបង្កើតសហគមន៍ថ្មី។ | ✓ | ✓ |
| ១៨ | ជំរឿនស្ថិតិគ្រឿងយន្តកសិកម្មឆ្នាំ២០១៦-២០១៧ និងតាមដានល្បឿនការងារភ្ជួររាស់ដីដោយគ្រឿងយន្តលើការបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦។ | ✓ | ✓ |
| ១៩ | បណ្ដុះបណ្ដាលបច្ចេកទេសក្រោយប្រមូលផលដល់កសិករ និងបន្តអនុវត្តគម្រោងតំបន់ទន្លេសាប។ | ✓ | ✓ |
| ២០ | បន្តតាមដាន និងត្រួតពិនិត្យសម្ភារកសិកម្មជាពិសេស ថ្នាំកសិកម្ម និងជីកសិកម្ម។ | ✓ | ✓ |
| ២១ | បន្តអប់រំ ណែនាំ និងផ្សព្វផ្សាយច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម អនុក្រិត្យ សារាចរណ៍ លិខិតបទដ្ឋាន និងប្រកាសនានា ដល់អាជីវករ ។ | ✓ | ✓ |
| ២២ | ពង្រឹងសមត្ថភាពបច្ចេកទេសផ្សព្វផ្សាយកសិកម្ម ដល់ភ្នាក់ងារផ្សព្វផ្សាយភូមិ តាមស្រុកគោលដៅ ។ | ✓ | ✓ |
| ២៣ | ប្រមូលចំណេះដឹង បទពិសោធន៍របស់កសិករឆ្នើម ដើម្បីផ្សព្វផ្សាយបច្ចេកទេសកសិកម្មឱ្យមានការរីកចម្រើនដល់ប្រជាកសិករ ។ | ✓ | ✓ |
| ២៤ | បន្តជំរឿនផ្ទៃដីចំការកៅស៊ូជាលក្ខណៈគ្រួសារ និងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និងលើកគម្រោងបណ្ដុះបណ្ដាល ពីបច្ចេកទេសដាំដុះនិងការថែទាំដល់កសិករ។ | ✓ | ✓ |

លេខ៖...............                                        សៀមរាប ថ្ងៃទី          ខែ            ឆ្នាំ ២០១៦

បានឃើញ និង ឯកភាព                                        **ប្រធានមន្ទីរ**

សៀមរាប ថ្ងៃទី          ខែ            ឆ្នាំ ២០១៦                **កសិកម្មខេត្តសៀមរាប**

**អភិបាល នៃគណៈអភិបាលខេត្ត**